## សាកលវិទ្យាល័យភូមិន្ទភ្នំពេញ




RUPP

# របាយការណ៍ស្តីពី
# លទ្ធភាពរកការងាររបស់និស្សិតក្រោយបញ្ចប់ការសិក្សា
# ក្នុងឆ្នាំ ២០២២

**សិក្សាស្រាវជ្រាវដោយ ការិយាល័យធានាគុណភាព**

បោះពុម្ពផ្សាយដោយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ កុម្ភៈ ២០២៣
ក្រោមគម្រោងRUPP-HEIP



រៀបចំដោយ៖លោក វង់ ធរី
លោកបណ្ឌិត សុខ សិរី
ការិយាល័យធានាគុណភាព

ការសិក្សាអំពីលទ្ធភាពស្វែងរកការងារធ្វើឆ្នាំ២០២២

របស់ក្រុមអតីតនិស្សិតដែលបានបញ្ចប់ការសិក្សា

ក្នុងឆ្នាំសិក្សា២០២១-២០២២

Quality Assurance Office,

RUPP - Quality Assurance Center

5th Floor, Building A

Royal University of Phnom Penh

Post Code: 12156

Russian Federation Boulevard, Toul Kork,

Phnom Penh, Cambodia

www.rupp.edu.kh/center/qac/

# បុព្វកថា

របាយការណ៍លទ្ធផលនៃការស្រាវជ្រាវពីស្ថានភាពនិស្សិតក្រោយពេលបញ្ចប់ការសិក្សាត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំដោយការិយាល័យធានាគុណភាពនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ការសិក្សានេះធ្វើឡើងជាមួយនឹងអតីតនិស្សិតចំនួន ១,១៤៥ នាក់ ដែលបានបញ្ចប់ការសិក្សាកាលពីឆ្នាំ២០២២ ក្នុងគោលបំណងស្វែងយល់ពីប្រសិទ្ធិភាពនៃកម្មវិធីសិក្សាប្រៀបធៀបលទ្ធផលរំពឹងទុករបស់កម្មវិធីសិក្សាជាមួយនឹងក្របខណ្ឌគុណវុឌ្ឍិជាតិ ការបណ្តុះបណ្តាលជំនាញ តម្រូវការទីផ្សារការងារ សមត្ថភាព និងលទ្ធភាពរបស់និស្សិតក្នុងការស្វែងរកការងារធ្វើ ទស្សនៈយល់ដឹង និងការវាយតម្លៃរបស់និស្សិតលើកម្មវិធីសិក្សាក្នុងការផ្តល់សេវាកម្មនៅក្នុងសាកលវិទ្យាល័យ ដែលជាធាតុចូលយ៉ាងសំខាន់សម្រាប់ជាមូលដ្ឋានកែលម្អកម្មវិធីសិក្សាឱ្យសមស្របតាមតម្រូវការសេដ្ឋកិច្ច-សង្គម។

លទ្ធផល ដែលទទួលបានពីការស្រាវជ្រាវនេះគឺជាសារមួយយ៉ាងសំខាន់សម្រាប់ព្រឹទ្ធបុរស-ព្រឹទ្ធបុរសរង ប្រធាន-អនុប្រធានដេប៉ាតឺម៉ង់ និងអ្នករៀបចំកម្មវិធីសិក្សាក្នុងការលើកកម្ពស់គុណភាពនៃវិធីសាស្ត្ររៀន និងបង្រៀន និងពង្រឹងសេវាអប់រំឲ្យកាន់តែប្រសើរ។

ក្នុងនាមគណៈគ្រប់គ្រងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ខ្ញុំសូមឯកភាពលើលទ្ធផលនៃការស្រាវជ្រាវខាងលើនេះ ដើម្បីប្រើប្រាស់ជាលទ្ធផលបែបវិទ្យាសាស្ត្រសម្រាប់ជាមូលដ្ឋានលើកកម្ពស់គុណភាពកម្មវិធីសិក្សា និងការកែលម្អការរៀន និងបង្រៀន ហើយខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយចំពោះលទ្ធផលរបាយការណ៍ស្រាវជ្រាវនេះ ដែលបានមកពីការខិតខំប្រឹងប្រែងរបស់ការិយាល័យធានាគុណភាព និងអង្គភាពពាក់ព័ន្ធ។ ខ្ញុំសង្ឃឹមថា អង្គភាពពាក់ព័ន្ធក្រោមឱវាទសាកលវិទ្យាល័យភូមិន្ទភ្នំពេញនឹងបន្តការចូលរួមសហការ និងសិក្សាស្វែងយល់អំពីប្រសិទ្ធភាពនៃកម្មវិធីសិក្សាឱ្យកាន់តែស៊ីជម្រៅ និងលម្អិតបន្ថែមទៀត។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២៣

**សាកលវិទ្យាធិការ**

**បណ្ឌិត ជេត ជាលី**

# សេចក្តីថ្លែងអំណរគុណ

ការិយាល័យធានាគុណភាពនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះថ្នាក់ដឹកនាំរបស់សាកលវិទ្យាល័យ និងភាគីពាក់ព័ន្ធទាំងអស់ដែលផ្តល់ការគាំទ្រដល់ការសិក្សាអំពីលទ្ធភាពស្វែងរកការងារធ្វើ ជាពិសេសក្រុមអតីតនិស្សិតដែលបានបញ្ចប់ការសិក្សាក្នុងឆ្នាំ២០២២ ដែលស្ម័គ្រចិត្តយល់ព្រមចូលរួមផ្តល់ទិន្នន័យសម្រាប់ការសិក្សាមួយនេះ។

ឆ្លៀតឱកាសដ៏ថ្លៃថ្លានេះ យើងខ្ញុំក្រុមការងារក្នុងគម្រោងRUPP-HEIP ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់នាយកដ្ឋានឧត្តមសិក្សាដែលបានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលចែករំលែកបទពិសោធន៍អំពីនីតិវិធីសិក្សាស្តីពីស្ថានភាពនិស្សិតក្រោយពីបញ្ចប់ការសិក្សា។ ការចូលរួមជំរុញ និងយកចិត្តទុកដាក់ពីនាយកដ្ឋានឧត្តមសិក្សាពិតជាបានធ្វើការសិក្សាមួយនេះមានដំណើរទៅយ៉ាងរលូន ជាពិសេសការផ្តល់ថវិកាកម្ចីរបស់ធនាគារពិភពលោកពិតជាបានរួមចំណែកធ្វើការសិក្សានេះ លេចចេញរូបរាងពិតប្រាកដឡើង។

របកគំហើញដែលបានរកឃើញតាមរយៈការសិក្សានេះ មិនគ្រាន់តែជាសក្ខីភាពឆ្លុះបញ្ចាំងអំពីប្រសិទ្ធិភាពការបណ្តុះបណ្តាលរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញកន្លងប៉ុណ្ណោះទេ តែលទ្ធផលនេះជាធាតុចូលដ៏សំខាន់មួយសម្រាប់កែលម្អកម្មវិធីសិក្សា ដើម្បីឆ្លើយតបតម្រូវការទីផ្សារការងារជាក់ស្តែងក្នុងសង្គមកម្ពុជា។

ជាថ្មីម្តងទៀត ការិយាល័យធានាគុណភាពនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ សង្ឃឹមថាថ្នាក់ដឹកនាំ និងភាគីពាក់ព័ន្ធទាំងអស់របស់សាកលវិទ្យាល័យ និងនាយកដ្ឋានឧត្តមសិក្សានឹងបន្តគាំទ្រជ្រោមជ្រែងលើការសិក្សាអំពីស្ថានភាពនិស្សិតក្រោយពីបញ្ចប់ការសិក្សាទៅមុខទៀត ដើម្បីធ្វើឱ្យប្រទេសកម្ពុជាមានមូលដ្ឋានទិន្នន័យគ្រប់គ្រាន់សម្រាប់សិក្សាវិភាគនៅក្នុងបណ្តាញអប់រំឧត្តមសិក្សាកម្ពុជា។

# មាតិកា


បញ្ជីក្រាហ្វិក - 2 -

បញ្ជីតារាង - 2 -

បញ្ជីរូបភាព - 2 -

មូលន័យសង្ខេប - 4 -

១.សេចក្តីផ្តើម - 5 -

១.១. សារៈសំខាន់នៃការសិក្សា - 5 -

២. វិធីសាស្រ្តស្រាវជ្រាវ - 7 -

២.១ ក្រមសីលធម៌ - 7 -

២.២ វិធីសាស្រ្តនិងឧបករណ៍ប្រមូលទិន្នន័យ - 8 -

២.៣ ទំហំគំរូតាងនិងសំណាក - 9 -

២.៤ ការប្រមូលទិន្នន័យ - 9 -

៣. លទ្ធផលសិក្សានិងការវិភាគទិន្នន័យ - 9 -

៣.១ លទ្ធផលអ្នកចូលរួមផ្តល់ព័ត៌មាន - 9 -

៣.២ ស្ថានភាពការងារនិស្សិតក្នុងពេលកំពុងសិក្សា - 13 -

៣.៥ រយៈពេលមានការងារធ្វើក្រោយពេលបញ្ចប់ការសិក្សា - 19 -

៣.៦ ស្ថាប័ននិស្សិតកំពុងបម្រើការងារក្រោយពេលបញ្ចប់ការសិក្សា - 19 -

៣.៧ ប្រាក់បៀវត្សទទួលបានប្រចាំខែ - 21 -

៣.៩ មធ្យោបាយស្វែងរកការងារធ្វើ - 28 -

៣.៩ ទស្សនៈនិស្សិតអំពីចំណេះដឹង និងអាជីព - 29 -

៣.១០ ទំនាក់ទំនងកម្មវិធីសិក្សា និងក្របខណ្ឌគុណវុឌ្ឍិជាតិ - 30 -

៣.១១ បំណងបន្តការសិក្សា - 37 -

៤.សេចក្តីសន្និដ្ឋាន - 38 -

៤.១ អនុសាសន៍ - 39 -

ឧបសម្ព័ន្ធ១ - 40 -

ឧបសម្ព័ន្ធ២៖កម្រងសំណួរ - 49 -

## បញ្ជីក្រាហ្វិក

ក្រាហ្វិក 1៖ គំរូតាងអ្នកចូលរួមតាមមហាវិទ្យាល័យ ...................................................... - 11 -
**ក្រាហ្វិក 2** ៖ ទីកន្លែងអតីតនិស្សិតសកភពប្រកបការងារតាមខេត្ត និងក្រុង ...................................... - 12 -
**ក្រាហ្វិក 3**៖ចំណាប់អារម្មណ៍របស់និស្សិតក្នុងការជ្រើសយកស.ភ.ភ.ព. ........................................ - 13 -
ក្រាហ្វិក 4៖ ស្ថានភាពនិស្សិតមានការងារធ្វើក្នុងពេលសិក្សានៅសកភព ............................................ - 14 -
ក្រាហ្វិក 5៖ ការពេញចិត្តចំពោះចំណេះដឹង ជំនាញ និងសមត្ថភាពទទួលបានពីស.ភ.ភ.ព .......................... - 15 -
ក្រាហ្វិក 6៖ លទ្ធភាពមានការងារធ្វើក្រោយបញ្ចប់ការសិក្សា ......................................................... - 17 -
ក្រាហ្វិក 7៖ ស្ថាប័នដែលនិស្សិតកំពុងបម្រើការក្រោយបញ្ចប់ការសិក្សា ............................................. - 17 -
ក្រាហ្វិក 8៖ អត្រាមានការងារធ្វើក្រោយបញ្ចប់ការសិក្សាតាមមហាវិទ្យាល័យ .......................................... - 18 -
ក្រាហ្វិក 9៖ រយៈពេលរកការងារធ្វើក្រោយបញ្ចប់ការសិក្សា .......................................................... - 19 -
ក្រាហ្វិក 10៖ ស្ថាប័នដែលនិស្សិតកំពុងធ្វើការងារក្រោយបញ្ចប់ការសិក្សា ........................................... - 20 -
ក្រាហ្វិក 11៖ ការប្រើប្រាស់ជំនាញ ចំណេះដឹង និងភាពងាយស្រួលសម្រាប់ការងារបច្ចុប្បន្ន ............................ - 21 -
ក្រាហ្វិក 12៖ ស្ថានភាពប្រាក់បៀវត្សប្រចាំខែ ........................................................................ - 22 -
ក្រាហ្វិក 13៖ការពេញចិត្តនិស្សិតលើការផ្តល់សេវាកម្ម ............................................................... - 27 -
ក្រាហ្វិក 14៖ការពេញចិត្តនិស្សិតលើការផ្តល់សេវាកម្ម ............................................................... - 28 -
ក្រាហ្វិក 15៖មធ្យោបាយរកការងារធ្វើក្រោយបញ្ចប់ការសិក្សា ......................................................... - 29 -
ក្រាហ្វិក 16៖ គោលបំណងបន្តការសិក្សា ............................................................................ - 38 -

## បញ្ជីតារាង

តារាង 1៖. ទំហំប្រាក់ខែនិស្សិតទទួលក្នុងពេលនិងក្រោយពេលបញ្ចប់ការសិក្សានៅស.ភ.ភ.ព ........................ - 22 -
តារាង 2៖ ទំនាក់ទងជលជះចំណេះដឹងទៅលើការងារ ................................................................. - 24 -

## បញ្ជីរូបភាព

រូបភាព 1 ៖ គំរូតាងភេទនិងអាយុអ្នកចូលរួម ........................................................................ - 10 -
រូបភាព 2៖. ការពេញចិត្តចំពោះការរៀន និងបង្រៀននៅ ស.ភ.ភ.ព ................................................. - 16 -
រូបភាព 3៖អត្ថប្រយោជន៍និស្សិតដែលជ្រើសយកការងារបច្ចុប្បន្ន ..................................................... - 23 -
រូបភាព 4៖ការពេញចិត្តលើកម្មវិធីសិក្សា ............................................................................ - 26 -
រូបភាព 5៖៖ទំនាក់ទំនងការសិក្សានិងជំនាញក្នុងការងារទីផ្សារ ...................................................... - 30 -
រូបភាព 6៖ការទំនាក់ទំនងនិងសមត្ថភាពក្នុងការធ្វើការជាក្រុម ..................................................... - 31 -

រូបភាព 7៖ភាពជាអ្នកដឹកនាំនិងសមត្ថភាពក្នុងការធ្វើការជាក្រុម ............................................................- 31 -
រូបភាព 8៖ សមត្ថភាពទំនាក់ទំនងនិងភាពជាអ្នកដឹកនាំ........................................................................ - 32 -
រូបភាព 9៖ សមត្ថភាពបច្ចេកវិទ្យាព័ត៌មាននិងភាពជាអ្នកដឹកនាំ................................................................ - 32 -
រូបភាព 10៖ចំណេះដឹងព័ត៌មានវិទ្យា និងសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ...................................... - 33 -
រូបភាព 11៖ភាពជាអ្នកដឹកនាំនិងសមត្ថភាពទំនាក់ទំនង ....................................................................... - 33 -
រូបភាព 12៖ភាពជាអ្នកដឹកនាំនិងសមត្ថភាពទំនាក់ទំនង ........................................................................- 34 -
រូបភាព 13៖ភាពជាអ្នកដឹកនាំនិងសមត្ថភាពទំនាក់ទំនង ........................................................................- 34 -
រូបភាព 14៖ទំនាក់ទំនងរវាងជំនាញភាពជាអ្នកដឹកនាំ និងចំណេះដឹងនៃការអភិវឌ្ឍន៍គំនិតផ្តួចផ្តើម ................ - 35 -
រូបភាព 15៖. ទំនាក់ទំនងចំណេះដឹងនៃការអភិវឌ្ឍន៍គំនិតផ្តួចផ្តើម និងជំនាញរួមចំណែកដល់កិច្ចការសង្គម..... - 35 -

# មូលន័យសង្ខេប

ការសិក្សាអំពីលទ្ធភាពស្វែងរកការងារធ្វើរបស់និស្សិតក្រោយពេលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មានគោលបំណងបង្ហាញពីប្រសិទ្ធភាពនៃការបណ្តុះបណ្តាលតាមឯកទេសនីមួយៗ ជាពិសេសដើម្បីស្វែងយល់អំពីសមត្ថភាពនិស្សិតក្នុងការបំពេញការងារ និងការផ្ទៀងផ្ទាត់កម្មវិធីសិក្សាទាំងអស់ជាមួយក្របខណ្ឌគុណវុឌ្ឍិជាតិដែលតម្រូវ ស្ថានភាពការងារបច្ចុប្បន្ន ហើយចំណេះនិងជំនាញដែលបានពីការសិក្សាកន្លងមក និងគុណភាពអប់រំដែលបានធ្វើឲ្យនិស្សិតពេញចិត្តក្នុងការជ្រើសរើសយកសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ការសិក្សាស្រាវជ្រាវនេះក៏ចង់ស្វែងយល់អំពីទស្សនៈផ្ទាល់ខ្លួនអតីតនិស្សិត ស្ថានភាពការងារមុនពេលចូលមកសិក្សាក្នុងសាកលវិទ្យាល័យ ពេលកំពុងសិក្សា និងស្ថានភាពស្វែងរកការងារធ្វើក្រោយពេលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ ប្រាក់បៀវត្សរ៍ ការវាយតម្លៃលើមុខវិជ្ជាដែលពាក់ព័ន្ធក្របខណ្ឌគុណវុឌ្ឍិជាតិ ចំណេះដឹងនិងជំនាញសតវត្សទី២១ និងគោលដៅបន្តសិក្សានាពេលអនាគត។ ដើម្បីទទួលបានព័ត៌មានទាំងនេះ ការិយាល័យធានាគុណភាពបានរៀបចំសិក្សាធ្វើឡើងជាមួយអតីតនិស្សិតដែលបានបញ្ចប់ការសិក្សាក្នុងឆ្នាំ២០២២ ដោយបានកំណត់គំរូតាង (Stratified Samples)សរុបចំនួន១១៤៥នាក់ សំណាកដែលទាញចេញពីក្នុងបំណែកគំរូតាងចំនួន**១១៤៥**នាក់ សំណាក(Sample Proportion, **p̂=1145)** តាមវិធីជ្រើសរើសគំរូតាងចៃដន្យ។

ជាលទ្ធផល យើងរកឃើញនិស្សិតមានការងារធ្វើ៦៤.៧%ភាគរយ(n=1133) បើធៀបមុនការចូលមកសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញគឺមានកំណើន៤៨.១% តែបើប្រៀបធៀបការងារពេញម៉ោងមុនចូលសិក្សា និងក្រោយបញ្ចប់ការសិក្សាមានការកើនឡើងរហូតដល់ទៅ៧៨.៦% ហើយបើប្រៀបធៀបការងារពេញម៉ោងក្នុងពេលកំពុងសិក្សា និងក្រោយបញ្ចប់ការសិក្សាមានកំណើន៦៦.២%។ ក្នុងចំណោមអ្នកមានការងារធ្វើទាំងអស់នោះ គឺមាននិស្សិតច្រើនជាងគេចំនួន៤៩%(n=733)បម្រើការងារក្នុងបណ្តាក្រុមហ៊ុនឯកជន និស្សិតចំនួន៣១.៥%បម្រើការងារក្នុងគ្រឹះស្ថានអប់រំឯកជន ហើយនិស្សិតចំនួន៦.៧%បម្រើការងារក្នុងអង្គការមិនមែនរដ្ឋាភិបាល និស្សិតចំនួន៤%បម្រើការងារក្នុងស្ថាប័នរដ្ឋ និស្សិត៣.២%បម្រើការងារក្នុងគ្រឹះស្ថានអប់រំសាធារណៈ និងមានតែ២.៧%ប៉ុណ្ណោះមានជំនួញផ្ទាល់ខ្លួន។ បច្ចុប្បន្ន និស្សិតភាគច្រើនទទួលបានប្រាក់បៀវត្សចាប់ពី២៥០ដុល្លា ដល់៣៥០ដុល្លា មាន៤០.៤% ប្រាក់បៀវត្សចាប់ពី៣៥១ដុល្លា ដល់៦៥០ដុល្លា មាន១៦% ប្រាក់បៀវត្សចាប់ពី៦៥១ដុល្លា ដល់១០០០ដុល្លា មាន១.៥% និងប្រាក់បៀវត្សច្រើនជាង១០០១ដុល្លាមាន០.៦% ។ តាមការអះអាងរបស់អតីតនិស្សិតជាង៧២%ដែលបានចូលរួមផ្តល់ចម្លើយក្នុងការស្រាវជ្រាវនេះបង្ហាញថាបានប្រើប្រាស់ពេលវេលាតិចជាង៣ខែដើម្បីទទួលបានការងារធ្វើ ហើយក្នុង៧៧.៨%កំពុងធ្វើការត្រូវតាមជំនាញ ហើយអតីតនិស្សិតជាង៧៥% បានបង្ហាញការពេញចិត្តចំពោះចំណេះដឹងនិងគុណភាពបណ្តុះបណ្តាលនៅសាកលវិទ្យាល័យនេះលើសពីការរំពឹងទុករបស់ពួកគេ។

# ១.សេចក្តីផ្តើម

ការសិក្សាអំពីស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សានេះត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំ ដើម្បីវាយតម្លៃគុណភាពនៃកម្មវិធីសិក្សារបស់នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ គោលបំណងសំខាន់នៃការសិក្សានេះគឺដើម្បីស្វែងយល់ពីចំណុចឆ្លើយតបលទ្ធផលសិក្សារំពឹងទុករបស់កម្មវិធីឯកទេសនីមួយៗ និងការរំពឹងទុកការងាររបស់និស្សិតក្រោយបានបញ្ចប់ការសិក្សា។ ការយល់ដឹងអំពីចំណុចប្រទាក់ក្រឡាគ្នានេះមានសារៈសំខាន់ខ្លាំងណាស់ ព្រោះវាផ្តល់នូវធាតុចូលចាំបាច់សម្រាប់ការរៀបចំរចនាសម្ព័ន្ធកម្មវិធីសិក្សាឡើងវិញ និងកែលម្អកម្មវិធីទាំងមូលដើម្បីតម្រង់ទិសនិស្សិតឱ្យត្រូវតាមតម្រូវការទីផ្សារការងារ។ ការសិក្សានេះធ្វើតែសម្រាប់និស្សិតដែលបានបញ្ចប់ការសិក្សានៅឆ្នាំ២០២២ថ្មីៗក្នុងកម្មវិធីអប់រំកម្រិតបរិញ្ញាបត្រគ្រប់ជំនាញ ដោយរួមទាំងនិស្សិតអាហារូបករណ៍ និងសិក្សាបង់ថ្លៃ។

បន្ថែមលើការស្រាវជ្រាវនេះ សាកលវិទ្យាល័យភូមិន្ទភ្នំពេញមានយន្តការនិងវិធានពិនិត្យតាមដាន វាយតម្លៃសកម្មភាពអប់រំបណ្តុះបណ្តាលជាប្រចាំ ហើយរបកគំហើញនៃលទ្ធផលសិក្សានឹងជួយដេប៉ាតឺម៉ង់កំណត់អំពីប្រសិទ្ធភាព និងប្រសិទ្ធផល កំណត់ចំណុចខ្លាំងនិងចំណុចត្រូវកែលម្អក្នុងកម្មវិធីសិក្សារបស់ដេប៉ាតឺម៉ង់ និងទំនាក់ទំនងរវាងការបណ្តុះបណ្តាលរបស់គ្រឹះស្ថានជាមួយនឹងតម្រូវការទីផ្សារការងារ។

របាយការណ៍ការសិក្សាត្រូវបានចែកចេញជាប្រាំមួយ(០៦)ផ្នែក៖ ផ្នែកសេចក្តីផ្តើមផ្តល់ទិដ្ឋភាពរួមនៃកម្មវិធីសិក្សារបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញផ្តល់សារៈសំខាន់និងគោលបំណងនៃការសិក្សា ផ្នែកទី២ បង្ហាញអំពីការវិភាគទិន្នន័យដែលប្រមូលបានពីក្រុមនិស្សិតដែលបានបញ្ចប់ការសិក្សា ផ្នែកទី៣ បង្ហាញពីរបកគំហើញសំខាន់ៗនៃការសិក្សា ផ្នែកទី៤ ផលជះនៃការសិក្សាសម្រាប់កែលម្អកម្មវិធី ផ្នែកទី៥ សេចក្តីសន្និដ្ឋានការរកឃើញ និងផ្នែកចុងក្រោយជាការផ្តល់នូវអនុសាសន៍។

## ១.១. សារៈសំខាន់នៃការសិក្សា

សាកលវិទ្យាល័យភូមិន្ទភ្នំពេញដែលចំណាស់ជាងគេជាគ្រឹះស្ថានសាធារណៈដែលយកចិត្តទុកលើការៀន និងបង្រៀន ការសិក្សាស្រាវជ្រាវនិងនវានុវត្តន៍ និងការចូលរួមសកម្មភាពសង្គម។ ការសិក្សាអំពីស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សាគឺជាការតាមដានលើស្ថានភាពនិស្សិតក្រោយចាកចេញពីសាកលវិទ្យាល័យទៅកាន់ទីផ្សារការងារ។ ការសិក្សានេះត្រូវបានរៀបចំដោយការិយាល័យធានាគុណភាពរបស់សាកលវិទ្យាល័យ ដើម្បីដឹងអំពីទីតាំងអតីតនិស្សិតដែលបានបញ្ចប់ការសិក្សាកំពុងធ្វើការនិងការអង្កេតអំពីលទ្ធភាពទទួលបានការងារធ្វើរបស់និស្សិតក្រោយពីបញ្ចប់ការសិក្សា ច្រកចូលទៅកាន់ទីផ្សារការងារ មុខរបរបច្ចុប្បន្ន និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលជាដើម។ ការស្រាវជ្រាវនេះក៏ជាវិធីរក្សាទំនាក់ទំនងនិងជាយន្តការទទួលយកមតិកែលម្អពីអតីតនិស្សិតដែលបានបញ្ចប់ការសិក្សាអំពីបទពិសោធន៍សិក្សារៀនសូត្ររបស់ពួកគេនៅក្នុងគ្រឹះស្ថាន ហើយនេះក៏ជាយន្តការសម្រាប់លើកកម្ពស់កិច្ចសហការរវាង អតីតនិស្សិតនិងនិស្សិតដែលកំពុងសិក្សា។ ការធ្វើបច្ចុប្បន្នភាពព័ត៌មានដែលទាក់ទងនឹងលទ្ធភាពទទួលបានការងាររបស់និស្សិត

បញ្ចប់ការសិក្សានាពេលកន្លងមកគឺជាធាតុចូលពីភាគីពាក់ព័ន្ធដែលបានទទួលអត្ថប្រយោជន៍ពីការសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។ សារៈសំខាន់នៃព័ត៌មានដែលទទួលបានពីការសិក្សានេះគឺជាមូលដ្ឋានគ្រឹះដែលចាំបាច់បំផុតសម្រាប់មហាវិទ្យាល័យ ដេប៉ាតឺម៉ង់ និងកម្មវិធី ដើម្បីពិនិត្យ និងកែលម្អកម្មវិធីសិក្សា ដើម្បីឆ្លើយតបតម្រូវការទីផ្សារការងារដែលអតីតនិស្សិតបម្រើការ។ លើសពីនេះ ការសិក្សានេះបង្ហាញអំពីជោគជ័យនិស្សិតដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញផង និងចង់ឱ្យនិស្សិតដឹងថាសាកលវិទ្យាល័យនៅតែយកចិត្តទុកដាក់និងនៅបន្តរក្សាទំនាក់ទំនងជាមួយពួកគាត់ផង។

កម្មវិធីសិក្សានៃសាកលវិទ្យាល័យភូមិន្ទមានគោលបំណងចូលរួមចំណែកលើកកម្ពស់គុណភាពនៃការអប់រំនៅក្នុងប្រទេស បន្តពង្រីកកម្មវិធីរបស់ខ្លួនដើម្បីដោះស្រាយតម្រូវការរបស់ប្រទេសជាតិ។ មកដល់ពេលនេះ កម្មវិធីសិក្សារបស់សាកលវិទ្យាល័យបានបណ្តុះបណ្តាលធនធាននិងមូលធនមនុស្សប្រកបដោយសមត្ថភាពនិងគុណភាពសម្រាប់ស្ថាប័នជាច្រើនក្នុងប្រទេសកម្ពុជានិងតំបន់ ហើយកម្មវិធីសិក្សាថ្មីៗជាច្រើនបានដាក់ឱ្យដំណើការ ដើម្បីបំពេញតម្រូវការគុណភាពអប់រំកម្រិតខ្ពស់ អ្នកបណ្តុះបណ្តាល និងអ្នកស្រាវជ្រាវក្នុងវិស័យអប់រំសម្រាប់វិស័យឯកជន និងសាធារណៈ។

កន្លងមកសាធារណៈជនជាច្រើនតែងតែយល់ថាការសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញគឺអាចក្លាយជាគ្រូបង្រៀនតែប៉ុណ្ណោះ។ តើការយល់ឃើញបែបនេះនៅពិតក្នុងកម្រិតណា? ក្រៅពីធ្វើជាបង្រៀន តើនិស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញអាចប្រកបរបរអ្វីខ្លះ? ដូច្នេះ ដើម្បីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយអំពីស្ថានភាពអតីតនិស្សិតដែលបានបញ្ចប់ការសិក្សាទាំងអស់នោះ សាកលវិទ្យាល័យភូមិន្ទភ្នំពេញបានរៀបចំសិក្សាស្រាវជ្រាវជាប្រចាំ ដើម្បីមានមូលដ្ឋានវិភាគលើកត្តាសំខាន់ដែលជះឥទ្ធិពលទៅលើបេសកកម្មរបស់សាកលវិទ្យាល័យ មហាវិទ្យាល័យ ដេប៉ាតឺម៉ង់ និងកម្មវិធីសិក្សានានា ហើយលទ្ធផលដែលទទួលបានអាចជាធាតុចូលសម្រាប់កែលម្អកម្មវិធីសិក្សាឲ្យបានសមស្របនឹងតម្រូវការទីផ្សារការងារផង និងដើម្បីឆ្លើយតបនិងក្របខណ្ឌគុណវុឌ្ឍិជាតិផងដែរ។

ជាមួយគ្នានេះ របកគំហើញដែលទទួលបានពីការស្រាវជ្រាវនេះគឺជាមូលដ្ឋានសម្រាប់វាស់វែងគុណភាពអប់រំដែលផ្តល់ដោយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ តាមរយៈភាពជោគជ័យក្នុងវិស័យការងារ ស្ថិរភាពការងារ ប្រាក់បៀវត្សនិងការប្រើប្រាស់ចំណេះដឹងដែលទទួលបានពីការសិក្សាក្នុងជំនាញឯកទេស។ ដូច្នេះការសិក្សានេះ គឺផ្តោតទៅលើកត្តាមួយចំនួនដូចខាងក្រោម៖

- កត្តាជះឥទ្ធិពលលើការងារដូចជា ភេទ ឯកទេសជំនាញ និងតម្រូវការទីផ្សារការងារដែលធ្វើឱ្យនិស្សិតទទួលបានជោគជ័យ។
- ទំនាក់ទំនងរវាងការសិក្សាទ្រឹស្តី និងការងារជាក់ស្តែង និងការយល់ដឹងអំពីការងារទីផ្សារដែលបុគ្គលម្នាក់ៗរំពឹងទុកដូចជា៖ ការពេញចិត្តចំពោះឱកាសការងារ ការរំពឹងទុកអំពីប្រាក់ចំណូល និងស្ថិរភាពការងារ ចំណេះដឹងនិងជំនាញដែលបានសិក្សាប្រើប្រាស់ក្នុងការងារប្រចាំថ្ងៃ។

- ការប្រើប្រាស់ចំណេះដឹង បទពិសោធន៍នៃការយល់ដឹង និងទស្សនៈផ្ទាល់ខ្លួនរបស់និស្សិតក្នុងការវាយតម្លៃលើកម្មវិធីសិក្សា ដើម្បីធ្វើជាមូលដ្ឋានវិភាគសម្រាប់កែលម្អកម្មវិធីសិក្សាក្នុងពេលអនាគត។
- ការប្រើប្រាស់និងតម្រូវការចំណេះដឹងនិងជំនាញសតវត្សទី២១។
- លទ្ធភាពសិក្សាអប់រំពេញមួយជីវិត។

## គោលបំណងនៃការសិក្សា

គោលបំណងនៃការសិក្សានេះគឺដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីលទ្ធភាពទទួលបានការងារធ្វើរបស់អតីតនិស្សិត ស្ថិរភាពការងារ និងអត្ថប្រយោជន៍មុខវិជ្ជាដែលពួកគាត់បានសិក្សា សមត្ថភាពប្រើប្រាស់ចំណេះដឹង និងជំនាញសតវត្សទី២១ ប្រាក់បៀវត្សប្រចាំខែក្នុងស្ថានភាពការងារដំបូង និងជំនាញដែលទីផ្សារការងារតម្រូវ។ ក្រៅពីនេះ ការសិក្សាស្រាវជ្រាវនេះ គឺបង្ហាញពីប្រសិទ្ធភាពនិងគុណភាពនៃការបណ្តុះបណ្តាល និងទំនាក់ទំនងរវាងគុណភាពកម្មវិធីសិក្សា ដែលឆ្លើយតបនឹងក្របខណ្ឌគុណវុឌ្ឍិជាតិតាមរយៈ៖

១. ការស្វែងយល់ពីប្រសិទ្ធភាព និងគុណភាពពាក់ព័ន្ធជាមួយកម្មវិធីសិក្សារបស់គ្រឹះស្ថាន ដោយផ្អែកលើលទ្ធផលទទួលបានការងាររបស់អតីតនិស្សិតដែលទើបបញ្ចប់ការសិក្សា និងលទ្ធភាពរកបានការងារធ្វើក្នុងរយៈពេលខ្លី
២. ការទទួលបាននិងប្រើបាស់ចំណេះដឹង និងជំនាញសតវត្សទី២១
៣. ការផ្តល់ជាតុចូលអំពីបទពិសោធន៍ដែលនិស្សិតបញ្ចប់ការសិក្សាបានឆ្លងកាត់កម្មវិធីសិក្សា ដើម្បីមានមូលដ្ឋានសម្រាប់បន្តការសិក្សាស្រាវជ្រាវអំពីស្ថានភាពឲ្យបានស៊ីជម្រៅ និងដើម្បីកែលម្អកម្មវិធីសិក្សា
៤. ការវាយតម្លៃរបស់និស្សិតដែលបញ្ចប់ការសិក្សាអំពីទំនាក់ទំនងទីផ្សារការងារតម្រូវ ជាមួយការច្នៃប្រឌិតក្នុងវិស័យអប់រំ និងការបង្កើតចំណេះដឹងសកល
៥. ភាពជោគជ័យនៃកម្មវិធីសិក្សារបស់គ្រឹះស្ថាន ទាក់ទងនឹងនិស្សិតបញ្ចប់ការសិក្សា និងឱកាសទទួលបានការងារ
៦. ការសិក្សាលើចំណុចខ្សោយនៃកម្មវិធីដែលត្រូវកែលម្អ និងធ្វើបច្ចុប្បន្នភាព ដើម្បីបំពេញនូវលទ្ធផលសិក្សាដែលរំពឹងទុក។

# ២. វិធីសាស្ត្រស្រាវជ្រាវ

## ២.១ ក្រមសីលធម៌

ក្រុមអ្នកស្រាវជ្រាវបានសន្យារក្សាការសម្ងាត់រាល់ទិន្នន័យផ្ទាល់ខ្លួនដែលអាចឈានទៅកំណត់អត្តសញ្ញាណអតីតនិស្សិតដែលជាភាគីចូលរួម។ដូច្នេះយើងខ្ញុំមិនរាយការណ៍អំពីលេខទូរស័ព្ទនិងអ៊ីម៉ែលរបស់អតីតនិស្សិតណាម្នាក់ឡើយ។ ដោយហេតុនេះការចូលរួមឆ្លើយសំណួរធ្វើឡើងជាមួយអតីតនិស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញដោយការ

ស្ម័គ្រចិត្តតាមរយៈខ្លឹមសារអំពីគោលស្ម័គ្រចិត្តនិងអត្ថប្រយោជន៍នៃការសិក្សាស្រាវជ្រាវដែលការព្រមព្រៀងផ្តល់ព័ត៌មាននេះមានជាលាយល័ក្ខអក្សរភ្ជាប់ជាមួយកម្រងសំណួរសម្រាប់។ ដូច្នេះ អ្នកចូលរួមមានសិទ្ធិគ្រប់គ្រាន់ក្នុងការដកខ្លួនចេញ ឬមិនចង់ផ្តល់ចម្លើយសម្រាប់សំណួរណាមួយដែលអ្នកចូលរួមផ្តល់ព័ត៌មានយល់ថាជាសិទ្ធិរបស់គេ ហើយក្រុមការងារស្រាវជ្រាវបានកំណត់ពេលវេលាសមស្របមួយ នៅពេលមិនបានទទួលព័ត៌មានត្រឡប់វិញទេ គឺសន្មត់ថាអ្នកចូលរួមបានបោះបង់ឱកាសក្នុងការផ្តល់ទិន្នន័យ។ តាមការវិភាគទិន្នន័យបានបង្ហាញថា អតីតនិស្សិតដែលបញ្ចប់ការសិក្សាក្នុងឆ្នាំ២០២២ ចំនួន០.៣% (N=1136) បានបដិសេដមិនចូលរួមការសិក្សានេះ។

## ២.២ វិធីសាស្ត្រនិងឧបករណ៍ប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យសម្រាប់ការសិក្សានេះធ្វើឡើងតាមការហៅទូរស័ព្ទ មុននឹងបញ្ជូនកម្រងសំណួរជាទម្រង់ Google Form ដែលតំណ(link) ទៅកាន់ក្រុមអតីតនិស្សិតដែលបានប្រឡងបញ្ចប់ និងទទួលបានជ័យលាភីក្នុងឆ្នាំ២០២២។ ដើម្បីមានទិន្នន័យគ្រប់គ្រាន់ ក្រុមការងារស្រាវជ្រាវបានក្រុមតេឡេក្រាមសម្រាប់បញ្ជូន តំណ(link) និងបានជម្រាបជូនគោលការណ៍ គោលបំណងសិក្សា និងបានសន្យាថានឹងរក្សាការសម្ងាត់សម្រាប់បុគ្គលម្នាក់ៗ តាមក្រមសីលធម៌ស្រាវជ្រាវ។ យើងបានប្រើប្រាស់វិធីសាស្ត្រតាមបែបវិភាគស្ថិតិនិងវិធីសាស្ត្រវិភាគទិន្នន័យ សម្រាប់ការបកស្រាយលទ្ធផលដែលអាចទុកចិត្តបាន ដោយប្រើប្រាស់កម្រងសំណួរជាឧបករណ៍សម្រាប់ប្រមូលព័ត៌មាននិងទិន្នន័យដែលទាក់ទងនឹងអតីតនិស្សិតដែលបានបញ្ចប់ការសិក្សាក្នុងឆ្នាំ២០២២។ កម្រងសំណួរដែលប្រើប្រាស់សម្រាប់សម្ភាសបានចែកចេញជាប្រាំមួយផ្នែកធំៗ ដែលផ្នែកទី១ពាក់ព័ន្ធព័ត៌មានផ្ទាល់ខ្លួននិស្សិតដែលផ្តោតជាចំបងលើសិទ្ធចូលរួម ភេទ អាយុ កន្លែងរស់នៅសព្វថ្ងៃ និងព័ត៌មានពាក់ព័ន្ធការសិក្សា។ ផ្នែកទី២ ទាក់ទងចំណេះដឹងជំនាញសតវត្សទី២១ ផ្នែកទី៣ ទាក់ទងនឹងបទពិសោធន៍ការងារក្នុងពេលសិក្សាក្នុងគ្រឹះស្ថាន ផ្នែកទី៤ទាក់ទងនឹងស្ថានភាពការងារក្រោយពេលបញ្ចប់ការសិក្សាផ្នែកទី៥គឺផ្តោតលើទស្សនៈនិស្សិតអំពីការសិក្សា និងតម្រូវការទីផ្សារការងារ ហើយផ្នែកទី៦ គឺការស្វែងយល់ពីការសិក្សាពេញមួយជីវិត។ កម្រងសំណួរដែលបានបំលែងជា Google Form រួចគឺធ្វើតំណ link ទៅឲ្យនិស្សិត១៦នាក់(Testing Sample Proportion, **p̂=16)** ដែលកំពុងបម្រើការងារជាបុគ្គលិកកិច្ចសន្យា ដើម្បីប្រាកដថាកម្រងសំណួរទាំងនោះជាឧបករណ៍សម្រាប់ប្រមូលព័ត៌មានដែលចង់បានពិតប្រាកដ។ ក្រោយទទួលបានលទ្ធផលពីការសាកល្បងយើងកែសម្រួលកម្រងសំណួរខ្លះដើម្បីឱ្យព័ត៌មានដែលអ្នកចូលរួមងាយយល់ហើយផ្តល់ទិន្នន័យនិងព័ត៌មានដែលក្រុមសិក្សាស្រាវជ្រាវចង់បាន។យើងបានកំណត់ទំហំគំរូតាងសំណាកតាមបែបចៃដន្យ (Stratified random Sampling) ដែលមានកម្រិតលំអៀង០.០៥ និងបានគណនាយ៉ាងហ្មត់ចត់សម្រាប់ការសិន្និដ្ឋានជារួម ដើម្បីឲ្យគំរូតាងទិន្នន័យដែលទទួលបានជាតំណាងឱ្យអ្នកបានបញ្ចប់ការសិក្សា(Graduate Population) ក្នុងឆ្នាំ២០២២។

### ២.៣ ទំហំគំរូតាងនិងសំណាក

សាកលវិទ្យាល័យភូមិន្ទភ្នំពេញមាននិស្សិតដែលបានបញ្ចប់ការសិក្សាក្នុងឆ្នាំ២០២២ ផ្នែកអាហារូបករណ៍ ប្រមាណជា១២.៣% និងនិស្សិតសិក្សាបង់ថ្លៃប្រមាណ៨៧.៧%។ ផ្អែកលើគំរូតាង**៤០១៥**សំណាក (Population, **4015)** ដែលបានបញ្ចប់ការសិក្សាឆ្នាំ២០២២ ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ យើងបានកំណត់យកទំហំគំរូតាង **១១៤៥**សំណាក (Sample, N**=1145)** តាមការជ្រើសរើសបែបចៃដន្យ(Stratified random Sampling) ពោលគឺស្មើនឹង២៨.២%នៃបំណែកគំរូតាង(Sample Proportion) នៃកម្រិតទុកចិត្ត៩៥%និងកម្រិតលំអៀង៥% ។

### ២.៤ ការប្រមូលទិន្នន័យ

ការិយាល័យធានាគុណភាពបានចាប់ផ្តើមប្រមូលព័តមានទំនាក់ទំនងរបស់និស្សិតដែលបានបញ្ចប់ការសិក្សាទាំងអស់ពីតាមការិយាល័យសិក្សារបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ នៅចន្លោះខែកក្កដា និងសីហា ហើយចាប់ផ្តើមរៀបចំកម្រងសំណួរ។ លុះដល់ដើមខែកញ្ញា យើងចាប់ផ្តើមជ្រើសរើសនិងបណ្តុះបណ្តាលអ្នកប្រមូលទិន្នន័យ ហើយសាកល្បងកម្រងសំណួរមុននឹងត្រូវយកទៅអនុវត្តក្នុងការប្រមូលព័ត៌មាន ដើម្បីធានាថាលទ្ធផលដែលប្រមូលបានអាចបំពេញគោលបំណងនៃការសិក្សានិងរបកគំហើញដែលអាចទទួលយកបានស្របតាមអ្វីដែលយើងចង់ស្វែងរក។ នៅពាក់កណ្តាលខែតុលា យើងចាប់ផ្តើមដំណើរការស្រាវជ្រាវតាមរយៈប្រព័ន្ធទូរស័ព្ទ Telegram និងOnline តាមទម្រង់Google Form តាមរយៈតំណ ហើយការប្រើប្រាស់ប្រព័ន្ធទំនាក់ទំនងតាមទូរស័ព្ទ រួមជាមួយTelegram អាចជួយឲ្យយើងសន្សំថវិកា និងពេលវេលាបានច្រើន ហើយលទ្ធផលក៏អាចទុកចិត្ត ដោយសារអ្នកផ្តល់ចម្លើយមានពេលគ្រប់គ្រាន់ក្នុងការផ្តល់ចម្លើយត្រឡប់មកវិញ។ សំណួរដែលប្រើប្រាស់ក្នុងការប្រមូលទិន្នន័យនេះ ភាគច្រើនតម្រូវឱ្យអ្នកឆ្លើយជ្រើសរើសនិទស្សន៍ជាលេខ ចំណែកចម្លើយដែលទទួលបានជាពាក្យពេចន៍ត្រូវបានបំលែងជាលេខកូដមុនបញ្ចូលក្នុងប្រព័ន្ធ SPSS សម្រាប់ធ្វើការវិភាគ ។ ការប្រមូលទិន្នន័យមានផលលំបាកខ្លះ ព្រោះអ្នកចូលរួមទទួលកម្រងសំណួរ ហើយតែមិនបំពេញ ហើយលេខទូរស័ព្ទជាច្រើនមិនអាចទំនាក់ទំនងបាន។

# ៣. លទ្ធផលសិក្សានិងការវិភាគទិន្នន័យ

### ៣.១ លទ្ធផលអ្នកចូលរួមផ្តល់ព័ត៌មាន

ការសិក្សាអំពីលទ្ធភាពស្វែងរកការងារធ្វើរបស់អតីតនិស្សិតគ្រប់ជំនាញឯកទេសដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញក្នុងឆ្នាំ២០២២។ អតីតនិស្សិតដែលចូលរួមការស្រាវជ្រាវនេះ គឺជាក្រុមនិស្សិតបរិញ្ញាបត្រអាហារូបករណ៍ចំនួន១៦.១% និងសិក្សាបង់ថ្លៃ៨៣.៩%ដែលមានគំរូតាង(Sample)ចំនួន**១១៣៣**(n=1133) សំណាក និស្សិតប្រុស៣៨% និងនិស្សិតស្រី៦២% ដែលតំណាងឲ្យអតីតនិស្សិតដែលបានបញ្ចប់ការសិក្សាក្នុងឆ្នាំ២០២២ចំនួន១១៤៥នាក់ (Sample Proportion **p̂=1145**) មានអាយុចន្លោះពី២២ទៅ២៥ឆ្នាំចំនួន៨៩.៦% ហើយនៅអាយុក្រោម២១ឆ្នាំ មានតែចំនួន៧.៧%តែប៉ុណ្ណោះ។ អ្នកចូលរួមក្នុងការសិក្សានេះមកពីមហាវិទ្យាល័យវិទ្យាសាស្ត្រ

ចំនួន៤៦.៤% មហាវិទ្យាល័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រចំនួន៣១.៦% មហាវិទ្យាល័យវិស្វកម្មចំនួន១២.២% វិទ្យាស្ថានភាសាបរទេសចំនួន៧.២%ហើយនឹងមហាវិទ្យាល័យសិក្សាអភិវឌ្ឍន៍មានចំនួនត្រឹមតែ២.៥%។

រូបភាព 1 ៖ គំរូតាងភេទនិងអាយុអ្នកចូលរួម







អតីតនិស្សិតទាំងនោះកំពុងបម្រើការទូទាំង២៥ខេត្តក្រុងក្នុងប្រទេសកម្ពុជា ក្នុងនោះអ្នកមានការងារក្នុងទីក្រុងភ្នំពេញមានចំនួន៧៥.៤% ខេត្តកណ្តាល៤.៥% តាកែវ២.៨% កំពង់ចាម២.៤% ខេត្តកំពង់ស្ពឺចំនួន១.៩% ខេត្តកំពតចំនួន១.៦% និងបណ្តាខេត្តផ្សេងៗចំនួន១១.៤% ។ តាមទិន្នន័យក៏បានបង្ហាញដែរថា អតីតនិស្សិតដែលបានបញ្ចប់ការសិក្សាចំនួន២៩.៦% កំពុងបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។

## និស្សិតចូលរួមផ្តល់ចម្លើយតាមមហាវិទ្យាល័យ




| | ម.វិទ្យាសាស្ត្រ | ម.សង្គមសាស្ត្រ និងមនុស្សសាស្ត្រ | ម.វិទ្យាវិស្វកម្ម | ម.សិក្សាអភិវឌ្ឍន៍ | ម.វិទ្យាស្ថានភាសាបរទេស |
|---|---|---|---|---|---|
| បញ្ចប់ | 1474 | 1224 | 148 | 60 | 1109 |
| ផ្តល់ចម្លើយ | 526 | 358 | 138 | 29 | 82 |
| ចម្លើយ% | 35.7 | 29.2 | 93.2 | 48.3 | 7.4 |
| N=1133 | 46.6 | 31.6 | 12.2 | 2.5 | 6.8 |

ក្រាហ្វិក 1៖ **គំរូតាងអ្នកចូលរួមតាមមហាវិទ្យាល័យ**

ក្រាហ្វិក២ ខាងក្រោមបង្ហាញអំពីរបាយទីតាំងរបស់អតីតនិស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញដែលកំពុងរស់នៅនិងបម្រើការងារក្នុងវិស័យនានាទូទាំង២៥ខេត្តក្រុងនៃព្រះរាជាណាចក្រកម្ពុជា។




ក្រាហ្វិក 2 ៖ ទីកន្លែងអតីតនិស្សិតសកភពប្រកបការងារតាមខេត្ត និងក្រុង

តាមទិន្នន័យដែលទទួលបានបង្ហាញថា ក្នុងពេលដែលកំពុងសិក្សាក្នុងសាកលវិទ្យាល័យភូមិន្ទភ្នំពេញមាននិស្សិតចំនួន២៥.២%កំពុងសិក្សានៅសាកលវិទ្យាល័យមួយផ្សេងទៀត ឬអាចនិយាយបានថាកំពុងសិក្សាពីរ(០២) សាកលវិទ្យាល័យក្នុងពេលតែមួយ។ ដូច្នេះមានហេតុមួយចំនួនដែលបង្ហាញថា អតីតនិស្សិតជ្រើសរើសមកសិក្សាក្នុងសាកលវិទ្យាល័យភូមិន្ទភ្នំពេញដោយសារតែ៖

### ក.គុណភាពក្នុងបណ្ដុះបណ្ដាល

- សាកលវិទ្យាល័យមានការបណ្ដុះបណ្ដាលប្រកបដោយគុណភាព ៦៣.៥%
- ផ្ដល់ទំនុកចិត្ត និងភាពល្បីល្បាញ៥៧.៣%
- ការបង្រៀនផ្ដោតលើការអនុវត្តជាក់ស្ដែង ៣៣.២%
- សាកលវិទ្យាល័យមានទាក់ទាញ ៣៤.៧%
- មានឱកាសទទួលបានការងារ ២៩.៣%

### ខ.កត្តាភូមិសាស្ត្រ និងថ្លៃសិក្សា

- ទទួលបានអាហារូបករណ៍ ២២.៩%
- សាកលវិទ្យាល័យមានទីតាំងជិតលំនៅដ្ឋាន ១៣.៤%

- សាកលវិទ្យាល័យអាចផ្តល់កន្លែងស្នាក់នៅ ៨.២%
- កត្តាផ្សេងៗ ១២.៣%




ក្រាហ្វិក 3៖ចំណាប់អារម្មណ៍របស់និស្សិតក្នុងការជ្រើសយកស.ភ.ភ.ព.

## ៣.២ ស្ថានភាពការងារនិស្សិតក្នុងពេលកំពុងសិក្សា

ទិន្នន័យនេះបង្ហាញថា មុនពេលចូលមកសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និស្សិតធ្លាប់មានការងារចំនួនត្រឹមតែ ១៦.៦% (n=186) ដែលសុទ្ធតែជាគ្រូបង្រៀន និងមន្ត្រីរាជការ ប៉ុន្តែចំនួនអ្នកមានការងារធ្វើបានកើនឡើងរហូតដល់ ៥៤.៣%។ ក្នុងពេលកំពុងសិក្សាចំនួនអ្នកមានការងារធ្វើពេញម៉ោងចំនួន៣៩.៨% ហើយចំនួន៥៧.៧%ទៀតមានការងារធ្វើមិនពេញម៉ោង ដែលភាគច្រើនបម្រើការឱ្យក្រុមហ៊ុនឯកជននានាចំនួន៤៩.៤% និងក្នុងវិស័យអប់រំឯកជន ២៥.២%។ និស្សិតដែលអាចរកការងារធ្វើកំឡុងពេលកំពុងសិក្សាមានឆ្នាំទី១ចំនួន១២.៨% ឆ្នាំទី២ចំនួន៣៥.៣% ឆ្នាំទីចំនួន១៦.៧% និងឆ្នាំទី៤ចំនួន១២.២%។

យើងអាចសន្និដ្ឋានថាពេលបានចូលមកសិក្សាក្នុងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និស្សិតបានស្វែងរកការងារធ្វើទៅតាមលទ្ធភាពរបស់ពួកគេពីឆ្នាំទី១ដល់ទី២ ប៉ុន្តែនៅឆ្នាំទី៤ដែលជាឆ្នាំបញ្ចប់ចំនួនអ្នកមានការងារធ្វើបានថយចុះដែលជាសញ្ញាណបង្ហាញថានិស្សិតបានងាកមកផ្តោតលើការសិក្សាវិញ។




ក្រាហ្វិក 4៖ ស្ថានភាពនិស្សិតមានការងារធ្វើក្នុងពេលសិក្សានៅសកភព

## ៣.៣ ចំណេះដឹងនិងជំនាញសតវត្សទី២១

យោងតាមការវិភាគទិន្នន័យជារួមដែលផ្តល់ដោយអ្នកចូលរួមបានបង្ហាញថាអតីតនិស្សិតបានវាយតម្លៃខ្ពស់ និងមានការពេញចិត្តចំពោះចំណេះដឹង ជំនាញ និងសមត្ថភាពដែលពួកគេទទួលបានពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ជាពិសេសសមត្ថភាពធ្វើការងារជាក្រុម ចំណេះដឹងក្នុងការគិត ជំនាញបម្រើការងារសង្គម សមត្ថភាពក្នុងការទំនាក់ទំនង និងឥរិយាបថទន់ភ្លន់។




Notes: WAI = Weight Average Index measured on a five-point scale [*Very low (VL) = 0.00-0.20, Low (L) = 0.21-0.40, Moderate (M) = 0.41-0.60, High (H) = 0.61-0.80, Very high (VH) = 0.81-1.00*]; OA = Overall Assessment.

ក្រាហ្វិក 5៖ ការពេញចិត្តចំពោះចំណេះដឹង ជំនាញ និងសមត្ថភាពទទួលបានពីស.ភ.ភ.ព

តាមការវិភាគទិន្នន័យដែលទទួលអំពីការពេញចិត្តរបស់និស្សិតបានបង្ហាញថា អតីតនិស្សិតបានវាយតម្លៃខ្ពស់លើកត្តាគ្រូបង្រៀនដែលមានអាកប្បកិរិយានិងក្រមសីលធម៌ក្នុងការបង្រៀនល្អ បង្រៀនមុខវិជ្ជាដែលត្រូវនឹងជំនាញ គ្រូមានបទពិសោធន៍ខ្ពស់ក្នុងការបង្រៀន និងមានគុណវុឌ្ឍិខ្ពស់។ ទន្ទឹមនឹងនេះ ពួកគេក៏បានវាយតម្លៃគ្រូបង្រៀនដែលបានយកលទ្ធផលស្រាវជ្រាវនិងរបកគំហើញថ្មីៗមកបង្រៀន ការប្រើប្រាស់ឧបករណ៍ និងសម្ភារៈបង្រៀនបានត្រឹមត្រូវ បានជួយជំរុញនិងលើកទឹកចិត្តដល់និស្សិតឱ្យខិតខំរៀនសូត្រ ការរៀបចំមេរៀននិងការបង្រៀនយកចិត្តទុកដាក់ និងការបញ្ចប់កម្មវិធីមេរៀនទាន់ពេលវេលា។




រូបភាព 2៖. ការពេញចិត្តចំពោះការរៀន និងបង្រៀននៅ ស.ភ.ភ.ព

Notes: WAI = Weight Average Index measured on a five-point scale [*Very low (VL) = 0.00-0.20, Low (L) = 0.21-0.40, Moderate (M) = 0.41-0.60, High (H) = 0.61-0.80, Very high (VH) = 0.81-1.00*]; OA = Overall Assessment.

## ៣.៤ ស្ថានភាពការងារនិស្សិតក្រោយពេលបញ្ចប់ការសិក្សា

ក្នុងការសិក្សានេះបានបង្ហាញថាក្រុមនិស្សិតដែលបញ្ចប់ការសិក្សាក្នុងឆ្នាំ២០២២ថ្មីៗនេះទទួលបានការងារធ្វើ ៦៤.៧% (n=1133) ដែលក្នុងនោះការងារពេញម៉ោង៨៧.៧% បើប្រៀបធៀបមុនការចូលមកសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញគឺចំនួនការងារមានកំណើន៤៨.២% ប៉ុន្តែបើប្រៀបធៀបការងារពេញម៉ោងក្នុងពេលកំពុងសិក្សា (២១.៥%) និងក្រោយបញ្ចប់ការសិក្សាមានកំណើន៦៦.២%។ ក្នុងចំណោមអ្នកមានការងារធ្វើទាំងអស់គឺមាននិស្សិត ៤៩%(n=733)បម្រើការងារក្នុងបណ្តាក្រុមហ៊ុនឯកជន និស្សិត៣១.៥%បម្រើការងារក្នុងគ្រឹះស្ថានអប់រំឯកជន និស្សិត៦.៧%បម្រើការងារក្នុងអង្គការមិនមែនរដ្ឋាភិបាល និស្សិត៥.១%បម្រើការងារក្នុងស្ថាប័នរដ្ឋ និស្សិត៣.២% បម្រើការងារក្នុងគ្រឹះស្ថានអប់រំសាធារណៈ និងចំនួន២.៧%មានជំនួញផ្ទាល់ខ្លួន។ យោងតាមទិន្នន័យវិភាគ យើងអាចធ្វើការសន្និដ្ឋានថា និស្សិតដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មានឱកាសច្រើនក្នុងការស្វែងរកការងារស្ថិរភាពពិតប្រាកដ។




ក្រាហ្វិក 6៖ លទ្ធភាពមានការងារធ្វើក្រោយបញ្ចប់ការសិក្សា




ក្រាហ្វិក 7៖ ស្ថាប័នដែលនិស្សិតកំពុងបម្រើការក្រោយបញ្ចប់ការសិក្សា

ក្រាហ្វិក៨ ខាងក្រោមគឺបង្ហាញអំពីអត្រានិស្សិតតាមមហាវិទ្យាល័យទទួលបានការងារបន្ទាប់ពីបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញក្នុងឆ្នាំ២០២២។ តាមការវិភាគលើទិន្នន័យដែលទទួលបានពីអតីតជ័យលាភីបង្ហាញថាភាគច្រើន (៤០%) នៃនិស្សិតដែលបញ្ចប់ការសិក្សាពីមហាវិទ្យាល័យវិទ្យាសាស្ត្រ មានឱកាសទទួលបានការងារច្រើន ចំណែកនិស្សិតបញ្ចប់ការសិក្សា(៣៤%)ដែលទទួលបានការងារច្រើនបន្ទាប់គឺមកពីមហាវិទ្យាល័យវិទ្យាសាស្ត្រសង្គមនិងមនុស្សសាស្ត្រ,និស្សិតដែលបញ្ចប់ការសិក្សា ពីមហាវិទ្យាល័យវិស្វកម្ម(១៤%)ជាក្រុមដែលមានឱកាសទទួលការងារបានច្រើនលំដាប់ទី៣ ចំណែកនិស្សិតវិទ្យាស្ថានភាសាបរទេស(៩%) មានឱកាសទទួលការងារ

បានច្រើនក្នុងលំដាប់ទី៤ និងក្រុមនិស្សិតបញ្ចប់ការសិក្សា៣% ពីមហាវិទ្យាល័យសិក្សាអភិវឌ្ឍន៍ (FDS)។ ផ្អែកលើការវិភាគទិន្នន័យបានបង្ហាញថាភាគរយនៃការឆ្លើយតបគឺទាក់ទងទៅនឹងសមាមាត្រនៃនិស្សិតបញ្ចប់ការសិក្សា ដែលមានន័យថាសមាមាត្រចំនួននៃនិស្សិតបញ្ចប់ការសិក្សាពីមហាវិទ្យាល័យដែលមានចំនួនអ្នកចូលរួមតិចតួចគឺដោយសារ ចំនួនអ្នកបញ្ចប់អ្នកបញ្ចប់ការសិក្សាមានបរិមាណតិចធៀបចំនួននិស្សិតបញ្ចប់ការសិក្សាសរុប ដូច្នេះលទ្ធផលអំពីការទទួលបានការងារធ្វើអាចមានតម្លៃគ្រប់គ្រាន់សម្រាប់តាងឱ្យសំណាក(តារាង)។ តាមការប្រៀបធៀបទិន្នន័យអាចសន្និដ្ឋានថាមហាវិទ្យាល័យដែលមានចំនួនអ្នកចូលរួមតិចតួចមិនមានបញ្ហាប្រឈមក្នុងការបកស្រាយទេ។ ម៉្យាងវិញទៀត តាមទិន្នន័យសម្រាប់តាមដានឱកាសការងារក្នុងចំណោមនិស្សិតបញ្ចប់ការសិក្សាបង្ហាញថា និស្សិតបញ្ចប់ការសិក្សាទាំងអស់មានឱកាសដូចៗគ្នាក្នុងការទទួលបានការងារ។ អ្វីដែលគួរឲ្យកត់សម្គាល់ គឺថានិស្សិតដែលបញ្ចប់ការសិក្សាភាគច្រើនអាចស្វែងរកការងាររៀងៗខ្លួននៅក្នុងទីក្រុងភ្នំពេញច្រើនជាងគេ(៧៦%) អាស្រ័យលើជំនាញនៃការសិក្សារបស់ពួកគេផងដែរ។ ក្នុងនេះគួរឱ្យកត់សម្គាល់ផងដែរថា ខេត្តមួយចំនួនដែលទទួលបាននិស្សិតបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញច្រើនបន្ទាប់ពីរាជធានីភ្នំពេញដូចជា ខេត្តកណ្តាល(៤%) កំពង់ចាម(៣%) កំពង់ស្ពឺ(២%) តាកែវ(២%) កំពត(២%)។




ក្រាហ្វិក ៨៖ អត្រាមានការងារធ្វើក្រោយបញ្ចប់ការសិក្សាតាមមហាវិទ្យាល័យ

## ៣.៥ រយៈពេលមានការងារធ្វើក្រោយពេលបញ្ចប់ការសិក្សា

ផ្អែកលើទិន្នន័យដែលផ្ដល់ដោយអ្នកចូលរួមបង្ហាញថា ក្រុមអតីតនិស្សិតដែលបានបញ្ចប់ការសិក្សាក្នុងឆ្នាំ ២០២២(n=734) ភាគច្រើន៧០.៨% បានអះអាងថាការសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញអាចជួយពួកគាត់រកការងារបានក្នុងរយៈពេលមួយតិចជាង៣ខែ ចំនួន៩.៧% ចំណាយពេលរកការងារធ្វើក្នុងរយៈពេលចន្លោះពី៣ខែទៅ ៦ខែ និង១៨.១%ចំណាយច្រើនជាង៦ខែ។




ក្រាហ្វិក 9៖ រយៈពេលរកការងារធ្វើក្រោយបញ្ចប់ការសិក្សា

## ៣.៦ ស្ថាប័ននិស្សិតកំពុងបម្រើការងារក្រោយពេលបញ្ចប់ការសិក្សា

តាមការវិភាគលើទិន្នន័យដែលទទួលបានបង្ហាញលទ្ធផលថា ក្នុងចំណោមអ្នកមានការងារធ្វើទាំងអស់នោះ គឺមាននិស្សិត៤៩% បម្រើការងារក្នុងបណ្ដាក្រុមហ៊ុនឯកជន និស្សិត៣១.៥%បម្រើការងារក្នុងគ្រឹះស្ថានអប់រំឯកជន និស្សិត៦.៧%បម្រើការងារក្នុងអង្គការមិនមែនរដ្ឋាភិបាល និស្សិត៥.១%បម្រើការងារក្នុងស្ថាប័នរដ្ឋ និស្សិត៣.២% បម្រើការងារក្នុងគ្រឹះស្ថានអប់រំសាធារណៈ និង២.៧%មានជំនួញផ្ទាល់ខ្លួន។




ក្រាហ្វិក 10៖ ស្ថាប័នដែលនិស្សិតកំពុងធ្វើការងារក្រោយបញ្ចប់ការសិក្សា

ក្រុមស្រាវជ្រាវបានស្វែងយល់ពីទំនាក់ទំនងការប្រើប្រាស់ចំណេះដឹង និងជំនាញដែលនិស្សិតបានសិក្សាសម្រាប់ស្ថានភាពការងារបច្ចុប្បន្នដែលនិស្សិតកំពុងធ្វើការក្រោយបន្ទាប់ពីបញ្ចប់ការសិក្សា ។ តាមការសិក្សាលើបានបង្ហាញឲ្យឃើញថា មាននិស្សិតដល់ចំនួន៧៧.៨%(n=733) បាននឹងកំពុងធ្វើការងារដែលបានប្រើប្រាស់ជំនាញ ហើយនិស្សិតចំនួន៨៦.៨% ទៀតបានបង្ហាញថាការសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញផ្ដល់ភាពងាយស្រួលក្នុងការរកការងារធ្វើ។ តាមសមាមាត្រនៃចំនួននិស្សិតដែលចូលរួមបង្ហាញថា និស្សិតគ្រប់មហាវិទ្យាល័យនិងវិតញ្ញាស្ថានទទួលបានការប្រើប្រាស់ជំនាញនិងភាពងាយស្រួលក្នុងការរកការងារប្រហាក់ប្រហែលគ្នា នេះបើផ្អែកលើលទ្ធផលការវិភាគតាមបែបតេស្ត Chi-square(P-*value*=0.001)។




| | ម.វិទ្យាសាស្ត្រ | ម.សង្គមសាស្ត្រ និងមនុស្សសាស្ត្រ | ម.វិទ្យាវិស្វកម្ម | ម.សិក្សាអភិវឌ្ឍន៍ | ម.វិទ្យាស្ថានភាសាបរទេស |
|---|---|---|---|---|---|
| ត្រូវជំនាញ | 38.4% | 38.6% | 14.5% | 2.5% | 10.3% |
| ងាយស្រួលរកការងារធ្វើ | 40.0% | 34.7% | 12.2% | 2.5% | 9.7% |

ក្រាហ្វិក 11៖ ការប្រើប្រាស់ជំនាញ ចំណេះដឹង និងភាពងាយស្រួលសម្រាប់ការងារបច្ចុប្បន្ន

## ៣.៧ ប្រាក់បៀវត្សទទួលបានប្រចាំខែ

តាមការផ្តល់ចម្លើយរបស់អ្នកចូលរួមបំពេញសំណួរបានបញ្ជាក់ឱ្យដឹងថា បច្ចុប្បន្ននិស្សិត៣៣% ទទួលបានប្រាក់បៀវត្សទាបជាងឬស្មើ២៥០ដុល្លា ហើយនិស្សិត២៣.៤%ទទួលបានប្រាក់បៀវត្សចាប់ពី២៥១ដុល្លា ដល់៤៥០ដុល្លា មាន៥៣% ប្រាក់បៀវត្សចាប់ពី៤៥១ដុល្លា ដល់៦៥០ដុល្លា មាន៨% ប្រាក់បៀវត្សចាប់ពី៦៥១ដុល្លា ដល់៨៥០ដុល្លា មាន៤% ប្រាក់បៀវត្សចាប់ពី៨៥១ដុល្លា ដល់១៥០០ដុល្លា មាន១.៣% និងប្រាក់បៀវត្សច្រើនជាង១៥០០ដុល្លា មាន០.៧% ។

ការធ្វើវិភាគតាមតេស្តANOVAបានបង្ហាញអំពីប្រាក់ចំណូលខុសគ្នាយ៉ាងខ្លាំងក្នុងចំណោមមហាវិទ្យាល័យ(P-*value*=0.000) ។ សម្រាប់អតីតនិស្សិតមកពីមហាវិទ្យាល័យវិទ្យាសាស្ត្រមានចំណូលទាបបំផុត១០០ដុល្លានិងប្រាក់ចំណូលខ្ពស់បំផុត២០០០ដុល្លាក្នុងមួយខែ អតីតនិស្សិតមកពីមហាវិទ្យាល័យវិស្វកម្មមានប្រាក់ចំណូលទាបបំផុត១០០ដុល្លា និងប្រាក់ចំណូលខ្ពស់លើសពី២០០០ដុល្លាក្នុងមួយខែ អតីតនិស្សិតមកពីមហាវិទ្យាល័យសង្គមសាស្ត្រនិងមនុស្សសាស្ត្រមានប្រាក់ចំណូលទាបបំផុត១០០ដុល្លានិងប្រាក់ចំណូលខ្ពស់បំផុត១៥០០ដុល្លាក្នុងមួយខែ សម្រាប់អតីតនិស្សិតមកពីវិទ្យាស្ថានភាសាបរទេសអាចរកប្រាក់ចំណូលទាបបំផុត១០០ដុល្លានិងប្រាក់ចំណូលខ្ពស់បំផុត១០០០ដុល្លាក្នុងមួយខែ ដោយឡែកអតីតនិស្សិតមកពីមហាវិទ្យាល័យសិក្សាអភិវឌ្ឍន៍មានប្រាក់ចំណូលទាបបំផុត១៥០ដុល្លា និងប្រាក់ចំណូលខ្ពស់បំផុត៤៥០ដុល្លាក្នុងមួយខែ ។ តាមការវិភាគទិន្នន័យបង្ហាញថា អ្នកដែលទទួលបាន

ប្រាក់បៀវត្សតិចតួចគឺជាអ្នកកំពុងហាត់ការ និងធ្វើការងារបណ្ដោះអាសន្ន ហើយអ្នកដែលមានប្រាក់បៀវត្សច្រើនបំផុតនោះគឺមានឋានៈជាប្រធាន។




ក្រាហ្វិក 12៖ ស្ថានភាពប្រាក់បៀវត្សប្រចាំខែ

តារាងខាងក្រោមបង្ហាញការប្រៀបធៀបអំពីប្រាក់ចំណូលនិស្សិតដែលទទួលក្នុងពេលកំពុងសិក្សា និងចំណូលទទួលបានក្រោយការសិក្សា

តារាង 1៖. *ទំហំប្រាក់ខែនិស្សិតទទួលក្នុងពេលនិងក្រោយពេលបញ្ចប់ការសិក្សានៅស.ភ.ភ.ព*

| ទំហំប្រាក់ចំណូលប្រចាំខែ | ស្រី (n=706) | ប្រុស (n=438) | សរុបរួម (n=1144) |
|---|---|---|---|
| ប្រាក់ចំណូលនិស្សិតទទួលក្នុងពេលកំពុងសិក្សានៅស.ភ.ភ.ព | | | |
| មិនផ្ដល់ចម្លើយ(គ្មានប្រាក់ចំណូល) | 51.0 | 42.0 | 47.6 |
| តិចជាង១០០ដុល្លា | 11.9 | 10.7 | 11.5 |
| ចន្លោះពី១០០ដុល្លាទៅ១៥០ដុល្លា | 14.0 | 12.8 | 13.5 |
| ចន្លោះពី១៥១ដុល្លាទៅ២០០ដុល្លា | 9.2 | 14.6 | 11.3 |
| ច្រើនជាង២០០ដុល្លា | 13.9 | 19.9 | 16.2 |
| ប្រាក់ខែនិស្សិតទទួលក្រោយពេលបញ្ចប់ការសិក្សានៅស.ភ.ភ.ព | | | |
| មិនផ្ដល់ចម្លើយ(គ្មានប្រាក់ចំណូល) | 35.1 | 37.0 | 35.8 |
| តិចជាង១០០ដុល្លា | 1.6 | 2.1 | 1.7 |
| ចន្លោះពី១០១ដុល្លាទៅ១៥០ដុល្លា | 4.5 | 3.7 | 4.2 |

| | | | |
|---|---|---|---|
| ចន្លោះពី១៥១ដុល្លាទៅ២៥០ដុល្លា | 17.8 | 15.8 | 17.0 |
| ចន្លោះពី២៥១ដុល្លាទៅ៣៥០ដុល្លា | 25.1 | 20.8 | 23.4 |
| ចន្លោះពី៣៥១ដុល្លាទៅ៤៥០ដុល្លា | 10.1 | 11.9 | 10.8 |
| ចន្លោះពី៤៥១ដុល្លាទៅ៥៥០ដុល្លា | 2.4 | 3.9 | 3.0 |
| ចន្លោះពី៥៥១ដុល្លាទៅ៦៥០ដុល្លា | 1.8 | 2.7 | 2.2 |
| ចន្លោះពី៦៥១ដុល្លាទៅ៧៥០ដុល្លា | 0.8 | 0.7 | 0.8 |
| ចន្លោះពី៧៥១ដុល្លាទៅ៨៥០ដុល្លា | 0.1 | 0.9 | 0.4 |
| ចន្លោះពី៨៥១ដុល្លាទៅ១០០០ដុល្លា | 0.1 | 0.5 | 0.3 |
| ចន្លោះពី១០០១ដុល្លាទៅ១៥០០ដុល្លា | 0.1 | 0.0 | 0.1 |
| ច្រើនជាង ២០០០ដុល្លា | 0.1 | 0.2 | 0.2 |

តាមការវិភាគទៅលើការពេញចិត្តសម្រាប់ការងារបច្ចុប្បន្នបង្ហាញថា និស្សិតមានទំហំការងារនិងការទទួលខុសត្រូវល្អ មានឱកាសប្រើប្រាស់ចំណេះដឹង និងបច្ចេកវិទ្យាដែលបានសិក្សាកន្លងមកបានច្រើន ទទួលបានការអភិវឌ្ឍន៍អាជីព និងជំនាញ កន្លែងបំពេញការងារមានបរិយាកាសល្អ។




រូបភាព 3៖អត្ថប្រយោជន៍និស្សិតដែលជ្រើសយកការងារបច្ចុប្បន្ន

Notes: WAI = Weight Average Index measured on a five-point scale [*Very low (VL) = 0.00-0.20, Low (L) = 0.21-0.40, Moderate (M) = 0.41-0.60, High (H) = 0.61-0.80, Very high (VH) = 0.81-1.00*]; OA = Overall Assessment.

ការព្យាករណ៍លើជំនាញគឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់អាជីពបច្ចុប្បន្នរបស់អតីតនិស្សិតដែលបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យនេះ។ ទម្រង់នៃការព្យាករណ៍បង្ហាញពីទំនាក់ទំនងការសិក្សាទ្រឹស្តីផ្សារភ្ជាប់ការអនុវត្តចំណេះដឹងនិងការប្រើជំនាញដែលនិស្សិតបានរៀនពីសាកលវិទ្យាល័យនេះដែលទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងការងារនិស្សិតដែលកំពុងធ្វើ ហើយមុខវិជ្ជាដែលអ្នកបានរៀនកន្លងមកមានសារៈសំខាន់សម្រាប់សង្គមកម្ពុជា។ ក្រោយបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និស្សិតចេះវិភាគនិងដោះស្រាយបញ្ហាប្រឈមក្នុងអាជីពរបស់ពួកគាត់ ហើយសាកលវិទ្យាល័យនេះក៏ជាទីកន្លែងដែលផ្តល់ ឱកាសឱ្យនិស្សិតទទួលបានការងារមានស្ថិរភាព មានជំនាញទំនាក់ទំនងការងារបានល្អ និងមានសមត្ថភាពក្នុងការប្រើប្រាស់កម្មវិធីទំនាក់ទំនងបច្ចេកវិទ្យាព័ត៌មាន។ ក្នុងនេះអតីតនិស្សិតបានសម្តែងការពេញចិត្តជាមួយនឹងចំណេះដឹងនិងគុណភាពនៃការអប់រំ និងមុខវិជ្ជាដែលបានបណ្តុះបណ្តាលនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ហើយដោយសារបានទទួលការបណ្តុះបណ្តាលនៅទីនេះ ទើបនិស្សិតមានឱកាសចាប់យកអាជីពបច្ចុប្បន្ន។

តាមការវិភាគបែប Linear region គឺក្នុងគោលបំណងព្យាករណ៍លើចំណេះដឹងដែលមានផលជះទៅលើការងារដែលនិស្សិតកំពុងធ្វើបន្ទាប់ពីបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញក្នុងឆ្នាំ២០២២ ។

តារាង 2៖ ***ទំនាក់ទងផលជះចំណេះដឹងទៅលើការងារ***

| **Attributes** | **B** | **Standard error** | **P-*value*** |
|---|---|---|---|
| (Constant-ថេរ) | 1.250 | .060 | ***.000*** |
| ជំនាញដែលអ្នកសិក្សានៅពីស.ភ.ភ.ព.ជួយអ្នកឲ្យទទួលបានអាជីពបច្ចុប្បន្នរបស់អ្នក | -.046 | .025 | .070 |
| មុខវិជ្ជាដែលអ្នកសិក្សានៅពីស.ភ.ភ.ព.បានជួយតម្រង់ទិសអ្នកឲ្យចាប់យកអាជីពបច្ចុប្បន្ន | -.005 | .027 | .863 |
| ការសិក្សានៅស.ភ.ភ.ព.បានផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្ត | .076 | .023 | **.001** |
| អ្នកកំពុងប្រើប្រាស់ចំណេះដឹងនិងជំនាញដែលបានសិក្សាពីស.ភ.ភ.ព. | -.017 | .027 | .524 |
| អ្នកកំពុងប្រើប្រាស់ចំណេះដឹងនិងជំនាញដែលបានសិក្សានៅស.ភ.ភ.ព.សម្រាប់ការងារបច្ចុប្បន្ន | -.033 | .028 | .226 |
| មុខវិជ្ជាទាំងអស់ដែលអ្នកសិក្សាមានប្រយោជន៍ចំពោះអាជីពអ្នកខ្លាំងណាស់ | .080 | .025 | **.001** |
| ជំនាញដែលបានការសិក្សាកន្លងមកមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយការងារដែលអ្នកកំពុងធ្វើ | .006 | .024 | .817 |
| ចំណេះដឹងដែលអ្នកទទួលបានពីស.ភ.ភ.ព.កំពុងតែជាតម្រូវការចាំបាច់សម្រាប់សង្គមកម្ពុជា | .013 | .025 | .588 |
| ការសិក្សានៅស.ភ.ភ.ព.ជួយអ្នកឲ្យមានសមត្ថភាពវិភាគនិងដោះស្រាយបញ្ហាប្រឈមនានាក្នុងការងារប្រចាំថ្ងៃ | .037 | .028 | .184 |

| | | | |
|---|---|---|---|
| ការសិក្សានៅស.ភ.ភ.ព.បានជួយឲ្យអ្នកមានឱកាសទទួលបានការងារមួយសមស្រប | -.090 | .029 | **.002** |
| ការសិក្សានៅស.ភ.ភ.ព.បានជួយឲ្យអ្នកមានសមត្ថភាពទំនាក់ទំនងការងារល្អ | -.010 | .030 | .728 |
| ការសិក្សានៅស.ភ.ភ.ព.បានជួយឲ្យអ្នកមានសមត្ថភាពច្នៃប្រឌិត | .051 | .027 | .063 |
| ការសិក្សានៅស.ភ.ភ.ពបានជួយអ្នកឲ្យមានសមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័តមាន(ICT) | -.065 | .024 | **.008** |
| ចំណេះនិងជំនាញរបស់អ្នកអាចជួយអ្នកបង្កើតសហគ្រិនភាពផ្ទាល់ខ្លួន | .002 | .022 | .929 |
| អ្នកទទួលបានចំណេះដឹងភាសាអង់គ្លេសពីស.ភ.ភ.ព.ល្មមប្រើប្រាស់បាន | .019 | .021 | .356 |
| កម្មវិធីសិក្សារបស់អ្នក តម្រូវឱ្យអ្នកចូលរួមហាត់ការមុនបញ្ចប់ការសិក្សា | .041 | .019 | **.030** |
| ហាត់ការឬចុះកម្មសិក្សាមុនបញ្ចប់ការសិក្សាជួយអ្នកឱ្យទទួលបានការងារបច្ចុប្បន្ន | -.005 | .020 | .818 |
| ក្រោយបញ្ចប់ការសិក្សា អ្នកមានសមត្ថភាពពេញលេញសម្រាប់បម្រើការងារបច្ចុប្បន្ន | -.072 | .026 | **.006** |
| អ្នកចង់ឲ្យមាននិស្សិតក្រោយៗសិក្សាមុខវិជ្ជាដូចអ្នកឲ្យបានច្រើន | -.035 | .023 | .131 |
| អ្នកពេញចិត្តជាមួយចំណេះដឹងនិងគុណភាពអប់រំដែលអ្នកបានទទួលពី ស.ភ.ភ.ព. | .075 | .026 | **.004** |

Notes: WAI = Weight Average Index measured on a five-point scale [*Very low (VL) = 0.00-0.20, Low (L) = 0.21-0.40, Moderate (M) = 0.41-0.60, High (H) = 0.61-0.80, Very high (VH) = 0.81-1.00*]; OA = Overall Assessment.

តាមលទ្ធផលព្យាករណ៍បង្ហាញថា កត្តាសំខាន់ៗមួយចំនួនដូចខាងក្រោមនេះ មានទំនាក់ទំនងជាមួយការទទួលបានការងារដែលមានស្ថេរភាព និងប្រាក់បៀវត្សប្រចាំខែ៖

(១) ការសិក្សានៅស.ភ.ភ.ព.បានផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្ត

(២) មុខវិជ្ជាទាំងអស់ដែលនិស្សិតបានសិក្សាមានប្រយោជន៍ចំពោះអាជីពបច្ចុប្បន្នខ្លាំងណាស់

(៣) ការសិក្សានៅស.ភ.ភ.ព.បានជួយឲ្យនិស្សិតមានឱកាសទទួលបានការងារមួយសមស្រប

(៤) ស.ភ.ភ.ពបានបណ្តុះសមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័តមាន(ICT)

(៥) និស្សិតដែលមានឱកាសហាត់ការមុនបញ្ចប់ការសិក្សាមានលទ្ធភាពទទួលបានការងារមានប្រាក់ខែខ្ពស់

(៦) ក្រោយបញ្ចប់ការសិក្សា និស្សិតមានសមត្ថភាពពេញលេញសម្រាប់បម្រើការងារបច្ចុប្បន្ន

(៧) និស្សិតពេញចិត្តជាមួយចំណេះដឹងនិងគុណភាពអប់រំដែលអ្នកបានទទួលពី ស.ភ.ភ.ព.។

ផ្អែកលើទិន្នន័យវិភាគនេះ យើងក៏អាចសន្និដ្ឋានថា អតីតនិស្សិតអាចទទួលបានប្រាក់ខែខ្ពស់ ខណៈដែលសាកលវិទ្យាល័យ (១) មានការកែលម្អកម្មវិធីសិក្សា ឱ្យឆ្លើយតបទៅនឹងទីផ្សារការងារ (២) ផ្តល់ជំនាញទន់សម្រាប់ការទំនាក់ទំនងនិងការងារជាក្រុម (៣) លើកកម្ពស់សមត្ថភាពសហគ្រិនភាព (៤) ផ្តល់ឱកាសឱ្យនិស្សិតហាត់ការ

តាមការិយាល័យក្នុងអំឡុងពេលសិក្សា (៥) បង្កើនសមត្ថភាពក្នុងការប្រើប្រាស់ភាសាអង់គ្លេសនិង (៦) ការកែលម្អសេវាកម្មប្រឹក្សាការងារសម្រាប់និស្សិតក្នុងសាកលវិទ្យាល័យ។




រូបភាព 4៖ការពេញចិត្តលើកម្មវិធីសិក្សា

Notes: WAI = Weight Average Index measured on a five-point scale [*Very low (VL) = 0.00-0.20, Low (L) = 0.21-0.40, Moderate (M) = 0.41-0.60, High (H) = 0.61-0.80, Very high (VH) = 0.81-1.00*]; OA = Overall Assessment.

ក្រាហ្វិកខាងក្រោមបង្ហាញការពេញចិត្តលើការផ្តល់សេវាកម្មរបស់សាកលវិទ្យាល័យ ហើយការសិក្សានេះធ្វើឡើង ដើម្បីលើកកម្ពស់ប្រសិទ្ធភាពប្រព័ន្ធការងារនិងកែលម្អចំណុចខ្វះខាត។ តាមការផ្តល់ចម្លើយរបស់អតីតនិស្សិតបង្ហាញថា សាកលវិទ្យាល័យបានផ្តល់សេវាកម្មល្អជាច្រើនចំណុច លើកលែងតែការផ្តល់សេវាកម្មលើប្រព័ន្ធInternet និង WiFi ដែលនិស្សិតយល់ថាមានភាពគ្រប់គ្រាន់សម្រាប់ពួកគាត់ ដូច្នេះសាកលវិទ្យាល័យគួរមានយន្តការណាមួយសមស្របដើម្បីឱ្យនិស្សិតដែលចូលមកសិក្សាទីនេះ មានលទ្ធភាពប្រើប្រាស់ប្រព័ន្ធInternet និង WiFi សម្រាប់ការសិក្សារបស់ពួកគេ។




ក្រាហ្វិក 13៖ការពេញចិត្តនិស្សិតលើការផ្តល់សេវាកម្ម

Notes: WAI = Weight Average Index measured on a five-point scale [*Very low (VL) = 0.00-0.20, Low (L) = 0.21-0.40, Moderate (M) = 0.41-0.60, High (H) = 0.61-0.80, Very high (VH) = 0.81-1.00*]; OA = Overall Assessment.

យោងតាមការវិភាគតម្លៃមធ្យមភាគ( Mean) ទទួលបានចន្លោះពី៦០%ទៅដល់៧៨%ដែលបង្ហាញថាការពេញចិត្តការផ្តល់សេវាកម្មមានកម្រិតខ្ពស់ ហើយបើពិនិត្យមើលតម្លៃ Standard Deviation មានចន្លោះពី០.១៩ ទៅ ០.២៤ ដែលបង្ហាញថាតម្លៃ Standard Deviation កាន់តែទាប គឺមានន័យថាការយល់ឃើញកាន់តែដូចគ្នា ហើយបើពិនិត្យជារួម និស្សិតដែលផ្តល់ការវាយតម្លៃនេះមានគំនិតប្រហាក់ប្រហែលគ្នាក្នុងការចូលរួមសកម្មភាពសង្គម។ តាមទិន្នន័យវិភាគបង្ហាញថា និស្សិតទាំងអស់មានគំនិតស្មើរតែដូចគ្នាក្នុងការបង្ហាញការពេញចិត្តខ្លាំងចំពោះឱកាសចូលរួមសកម្មភាពសង្គម ដែលសាកលវិទ្យាល័យបានផ្តល់ឱ្យពួកគេកំឡុងពេលសិក្សា។




ក្រាហ្វិក 14៖ការពេញចិត្តនិស្សិតលើការផ្តល់សេវាកម្ម

Notes: WAI = Weight Average Index measured on a five-point scale [*Very low (VL) = 0.00-0.20, Low (L) = 0.21-0.40, Moderate (M) = 0.41-0.60, High (H) = 0.61-0.80, Very high (VH) = 0.81-1.00*]; OA = Overall Assessment.

## ៣.៩ មធ្យោបាយស្វែងរកការងារធ្វើ

ការប្រមូលទិន្នន័យអំពីរបៀបអតីតនិស្សិតស្វែងរកការងារធ្វើ គឺក្នុងគោលបំណងពិនិត្យមើលប្រសិទ្ធភាពលើយន្តការផ្តល់សេវាកម្មដែលមានស្រាប់របស់គ្រឹះស្ថាន និងមធ្យោបាយផ្សេងៗដែលនិស្សិតប្រើប្រាស់ ដើម្បីទទួលបានការងារធ្វើ។ តាមទិន្នន័យដែលទទួលបានបង្ហាញលទ្ធផលថា និស្សិតភាគច្រើនមិនបានប្រើប្រាស់សេវាកម្មដែលផ្តល់ដោយគ្រឹះស្ថានទេ ហើយមធ្យោបាយដែលនិស្សិតរកការងារធ្វើច្រើនជាងគេ គឺតាមរយៈតាមប្រព័ន្ធអ៊ីនធឺណែត៣៨.១%(n=1145) និងតាមរយៈទទួលព័ត៌មានពីសាច់ញាតិមិត្តភ័ក្ត ឬគ្រួសារបានរហូតដល់ចំនួន២៧.៩% ទាក់ទងផ្ទាល់ជាមួយនិយោជកមានចំនួន១៣.៨% និងតាមការបិតផ្សាយសាធារណៈ១២.៤%។ តាមការសន្និដ្ឋានការិយាល័យប្រឹក្សាវិជ្ជាជីវៈ សមាគមន៍និស្សិត និងប្រព័ន្ធផ្សព្វផ្សាយរបស់គ្រឹះស្ថានមិនមានឥទ្ធិពលទៅការស្វែងរកការងារធ្វើរបស់និស្សិតទេ ឬអាចនិយាយបានថាកត្តាអសកម្មនេះអាចបណ្តាលមកពីការរាតត្បាតនៃជម្ងឺកូវីដ-១៩ក្នុងចន្លោះបីឆ្នាំចុងក្រោយនេះ។ ដូច្នេះ ប្រព័ន្ធផ្តល់សេវាកម្មដែលមានស្រាប់របស់គ្រឹះស្ថានគប្បីពិនិត្យមើលសកម្មភាពជួយនិស្សិតក្នុងការស្វែងរកការងារឡើងវិញ។




ក្រាហ្វិក 15៖មធ្យោបាយរកការងារធ្វើក្រោយបញ្ចប់ការសិក្សា

## ៣.៩ ទស្សនៈនិស្សិតអំពីចំណេះដឹង និងអាជីព

តាមការប្រមូលទិន្នន័យអំពីទស្សនៈអតីតនិស្សិតបានបង្ហាញឲ្យឃើញថា និស្សិតចំនួន៩៩%(n=1145) ទទួលស្គាល់ថាពួកគេទទួលបានបំណិននិងចំណេះដឹងសតវត្សទី២១បានល្អ និងនិស្សិតចំនួន៦៤.៧%(n=1133) ទៀត យល់ឃើញថាទីផ្សារការងារតម្រូវឱ្យមានបំណិនសតវត្សទី២១ ច្រើនជាងធ្វើដែលគ្រឹះស្ថានបានផ្ដល់ឱ្យពួកគេ។ ក្នុងចំណោមអតីតនិស្សិតចំនួន៧៧.៨%(n=733)បានអះអាងថាកំពុងប្រើប្រាស់ចំណេះដឹង និងជំនាញដែលទទួលបានពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងនិស្សិតចំនួន៨៦.៨%ទៀតយល់ឃើញថាការសិក្សានៅក្នុងគ្រឹះស្ថាននេះបានផ្ដល់ភាពងាយស្រួលដល់ពួកគេក្នុងការទទួលបានអាជីពបច្ចុប្បន្ន។




រូបភាព 5៖៖ទំនាក់ទំនងការសិក្សានិងជំនាញក្នុងការងារទីផ្សារ

Notes: WAI = Weight Average Index measured on a five-point scale [*Very low (VL) = 0.00-0.20, Low (L) = 0.21-0.40, Moderate (M) = 0.41-0.60, High (H) = 0.61-0.80, Very high (VH) = 0.81-1.00*]; OA = Overall Assessment.

## ៣.១០ ទំនាក់ទំនងកម្មវិធីសិក្សា និងក្របខណ្ឌគុណវុឌ្ឍិជាតិ

នៅក្នុងក្របខណ្ឌគុណវុឌ្ឍិជាតិ គឺតម្រូវឲ្យកម្មវិធីថ្នាក់បរិញ្ញាបត្រមានរំលេចនូវ ចំណេះដឹង ជំនាញក្នុងការគិត ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យានិងទំនាក់ទំនង និងជំនាញចិត្តចលនា។ តារាងខាងក្រោមបង្ហាញពីភាពឆ្លើយតបក្របខណ្ឌគុណវុឌ្ឍិជាតិ។

តាមការវិភាគទិន្នន័យទាក់ទងចំណេះដឹងដែលទទួលបានពីការសិក្សា បង្ហាញថាកម្មវិធីសិក្សារបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ មានលក្ខណៈឆ្លើយតបក្របខណ្ឌគុណវុឌ្ឍិជាតិពេញលេញតាមរយៈការប្រៀបធៀបជំនាញទំនាក់ទំនងជាមួយនឹង (៦) សមត្ថភាពក្នុងការធ្វើការជាក្រុម (៧) ចំណេះដឹងផ្នែកព័ត៌មានវិទ្យា; និង (៨) ជំនាញភាពជាអ្នកដឹកនាំ។ តាមការវិភាគអំពីទំនាក់ទំនង( Correlation analysis )បង្ហាញឱ្យឃើញថា ជំនាញទំនាក់ទំនងមានភាពរឹងមាំ និងមានលក្ខណៈជាវិជ្ជមានទាក់ទងនឹងចំណេះដឹងក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងជំនាញភាពជាអ្នកដឹកនាំ។

តាមការវិភាគយើងអាចសន្និដ្ឋានបានយ៉ាងច្បាស់ថាជំនាញលើសមត្ថភាពទំនាក់ទំនងមានអត្ថប្រយោជន៍ខ្លាំងណាស់សម្រាប់និស្សិតក្នុងពេលបំពេញការងារ។

នៅពេលដែលនិស្សិតទទួលបានចំណេះដឹងនិងសមត្ថភាពលើជំនាញទំនាក់ទំនងល្អ ពួកគេក៏អាចមានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា និងមានជំនាញភាពជាអ្នកដឹកនាំបានល្អផងដែរ។

រូបភាព 6៖ការទំនាក់ទំនងនិងសមត្ថភាពក្នុងការធ្វើការជាក្រុម




P-*value* =0.01 level (2-tailed)

និស្សិតធ្វើការជាក្រុមមានប្រសិទ្ធិភាពខ្ពស់អាស្រ័យលើពួកគេមានសមត្ថភាពក្នុងការទំនាក់ទំនងល្អ។

រូបភាព 7៖ភាពជាអ្នកដឹកនាំនិងសមត្ថភាពក្នុងការធ្វើការជាក្រុម




P-*value* =0.01 level (2-tailed)

និស្សិតធ្វើការជាក្រុមមានប្រសិទ្ធិភាពអាស្រ័យលើពួកគេមានសមត្ថភាពក្នុងការដឹកនាំ។

រូបភាព 8៖ សមត្ថភាពទំនាក់ទំនងនិងភាពជាអ្នកដឹកនាំ




P-*value* =0.01 level (2-tailed)

និស្សិតមានភាពជាអ្នកដឹងនាំល្អ អាស្រ័យលើពួកគេមានសមត្ថភាពទំនាក់ទំនងល្អ ។

រូបភាព 9៖ សមត្ថភាពបច្ចេកវិទ្យាព័ត៌មាននិងភាពជាអ្នកដឹកនាំ




P-*value* =0.01 level (2-tailed)

និស្សិតមានសមត្ថភាពទំនាក់ទំនងល្អអាស្រ័យលើពួកគេមានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាបានល្អ។

រូបភាព 10៖ចំណេះដឹងព័ត៌មានវិទ្យា និងសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន




P-*value* =0.01 level (2-tailed)

និស្សិតមានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាបានល្អអាស្រ័យលើពួកគេមានចំណេះដឹងខាងបច្ចេកវិទ្យាព័ត៌មាន។

រូបភាព 11៖ភាពជាអ្នកដឹកនាំនិងសមត្ថភាពទំនាក់ទំនង




P-*value* =0.01 level (2-tailed)

និស្សិតមានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាបានល្អអាស្រ័យលើពួកគេមានចំណេះដឹងខាងភាសាអង់គ្លេស។

រូបភាព 12៖ភាពជាអ្នកដឹកនាំនិងសមត្ថភាពទំនាក់ទំនង




P-*value* =0.01 level (2-tailed)

និស្សិតមានសមត្ថភាពវិភាគទិន្នន័យបានល្អអាស្រ័យលើពួកគេមានសមត្ថភាពស្រាវជ្រាវខ្ពស់ ។

រូបភាព 13៖ភាពជាអ្នកដឹកនាំនិងសមត្ថភាពទំនាក់ទំនង




P-*value* =0.01 level (2-tailed)

និស្សិតមានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាបានល្អជាកត្តានាំពួកគេមានសមត្ថភាពវិភាគទិន្នន័យល្អ។

រូបភាពទី១៤ និងរូបភាពទី១៥ បង្ហាញពីទំនាក់ទំនងដ៏រឹងមាំ និងលក្ខណៈវិជ្ជមានរវាងជំនាញភាពជាអ្នកដឹកនាំ និងចំណេះដឹងនៃការអភិវឌ្ឍគំនិតផ្តួចផ្តើម។ ការវិភាគក៏បង្ហាញផងដែរអំពីទំនាក់ទំនងដ៏រឹងមាំ និងវិជ្ជមានរវាងចំណេះដឹងនៃការអភិវឌ្ឍគំនិតផ្តួចផ្តើម ជាមួយនឹងជំនាញដែលរួមចំណែកដល់កិច្ចការសង្គម។ និស្សិតដែលបានបញ្ចប់

ការសិក្សាមានជំនាញភាពជាអ្នកដឹកនាំល្អ មានទំនោរនិងសមត្ថភាពខ្ពស់លើចំណេះដឹងនៃការអភិវឌ្ឍន៍គំនិតផ្តួចផ្តើម និងបទពិសោធន៍ដើម្បីធ្វើការក្នុងការរួមចំណែកក្នុងកិច្ចការសង្គម។

រូបភាព 14៖ ទំនាក់ទំនងរវាងជំនាញភាពជាអ្នកដឹកនាំ និងចំណេះដឹងនៃការអភិវឌ្ឍន៍គំនិតផ្តួចផ្តើម




P-*value* =0.01 level (2-tailed)

រូបភាព 15៖. ទំនាក់ទំនងចំណេះដឹងនៃការអភិវឌ្ឍន៍គំនិតផ្តួចផ្តើម និងជំនាញរួមចំណែកដល់កិច្ចការសង្គម




P-*value* =0.01 level (2-tailed)

សរុបសេចក្តីមក តាមរយៈការសិក្សាអំពីលទ្ធភាពរកការងារធ្វើរបស់និស្សិតក្រោយបញ្ចប់ការសិក្សាក្នុងឆ្នាំ ២០២២ បានបង្ហាញថា ការសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញនៅតែជាកន្លែងបណ្តុះបណ្តាល ដែលប្រកបដោយគុណភាពខ្ពស់ និងឱកាសការងារច្រើនសម្រាប់និស្សិត។

## ប្រសិទ្ធភាព

- អត្រាមានការងារធ្វើក្រោយបញ្ចប់ការសិក្សាធ្វើ៦៤.៧%ភាគរយ(n=1133)
- អត្រាមានការងារធ្វើពេញម៉ោង បើប្រៀបធៀបមុនចូលរៀនកើនឡើងរហូតដល់ទៅ ៧៨.៦%
- អត្រាមានការងារធ្វើពេញម៉ោង បើប្រៀបធៀបពេលកំពុងសិក្សាមានកំណើន ៦៦.២%
- រយៈពេលទទួលបានការងារធ្វើក្រោយបញ្ចប់ការសិក្សាតិចជាង៣ខែ មាន ៧២%
- អត្រាធ្វើការងារត្រូវតាមជំនាញ ៧៧.៨%
- ភាពងាយស្រួលរកការងារធ្វើក្រោយបញ្ចប់ពីស.ភ.ភ.ព ៨៦.៨%

## ប្រសិទ្ធផល (n=1133)

ការទទួលបានតួនាទីតាមកន្លែងធ្វើការ

- ប្រធាន ០.៨%
- អនុប្រធាន ០.៤%
- អ្នកគ្រប់គ្រងផ្នែក ៤%
- អ្នកបច្ចេកទេស ៦.៩%
- គ្រូបង្រៀនពេញសិទ្ធ ១១.៧%
- គ្រូបង្រៀនកិច្ចសន្យា ៩.៨%
- បុគ្គលិក/មន្ត្រីពេញសិទ្ធ ២៤.៧%
- បុគ្គលិកកិច្ចសន្យា ១២%
- អ្នកហាត់ការលើជំនាញ ៦.១%
- ការងារបណ្ដោះអាសន្ន ៨.៦%
- ផ្សេងៗ ១៥%

ស្ថានភាពប្រាក់បៀវត្សទូទៅ

- តិចជាង១០០ដុល្លា ១.៧%
- ចន្លោះពី១០១ដុល្លាទៅ ១៥០ដុល្លា៤.២%
- ចន្លោះពី១៥១ដុល្លាទៅ ២៥០ដុល្លា ១៧%
- ចន្លោះពី២៥១ដុល្លាទៅ ៣៥០ដុល្លា ២៣.៤%
- ចន្លោះពី៣៥១ដុល្លាទៅ ៤៥០ដុល្លា ១០.៨%
- ចន្លោះពី៤៥១ដុល្លាទៅ ៥៥០ដុល្លា ៣.០%
- ចន្លោះពី៥៥១ដុល្លាទៅ ៦៥០ដុល្លា ២.២%

- ចន្លោះពី៦៥១ដុល្លាទៅ ៧៥០ដុល្លា ០.៨%
- ចន្លោះពី៧៥១ដុល្លាទៅ ៨៥០ដុល្លា ០.៤%
- ចន្លោះពី៨៥១ដុល្លាទៅ ១០០០ដុល្លា ០.៣%
- ចន្លោះពី១០០១ដុល្លាទៅ ១៥០០ដុល្លា ០.១%
- ចន្លោះពី១៥០១ដុល្លាទៅ ២០០០ដុល្លា ០.២%
- ច្រើនជាង ២០០០ដុល្លា ០.៣%

**ផលជះនៃចំណេះដឹង** (n=1133)

- និស្សិតមកពីមហាវិទ្យាល័យវិទ្យាសាស្ត្រមានការងារធ្វើ ៤០.៣%
- និស្សិតមកពីមហាវិទ្យាល័យសង្គមសាស្ត្រនិងមនុស្សសាស្ត្រមាន មានការងារធ្វើ ៣៣.៧%
- និស្សិតមកពីមហាវិទ្យាល័យវិស្វកម្មមានមានការងារធ្វើ ១៣.៨%
- និស្សិតមកពីវិទ្យាស្ថានភាសាបរទេសមានការងារធ្វើ ៩%
- និស្សិតមកពីមហាវិទ្យាល័យសិក្សាអភិវឌ្ឍន៍មាន មានការងារធ្វើ ៣.២%

## ការប្រើប្រាស់ចំណេះដឹង

| | |
|---|---|
| • មុខវិជ្ជាទាំងអស់ដែលអ្នកសិក្សាមានប្រយោជន៍ចំពោះអាជីពអ្នកខ្លាំងណាស់ | 0.72 |
| • ជំនាញដែលបានការសិក្សាកន្លងមកមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយការងារដែលអ្នកកំពុងធ្វើ | 0.72 |
| • ការសិក្សានៅស.ភ.ភ.ព.បានផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្ត | 0.71 |
| • អ្នកកំពុងប្រើប្រាស់ចំណេះដឹងនិងជំនាញដែលបានសិក្សាពីស.ភ.ភ.ព. | 0.69 |
| • អ្នកកំពុងប្រើប្រាស់ចំណេះដឹងនិងជំនាញដែលបានសិក្សានៅស.ភ.ភ.ព.សម្រាប់ការងារបច្ចុប្បន្ន | 0.69 |
| • ការសិក្សានៅស.ភ.ភ.ព.បានជួយឲ្យអ្នកមានសមត្ថភាពទំនាក់ទំនងការងារល្អ | 0.69 |
| • អ្នកទទួលបានចំណេះដឹងភាសាអង់គ្លេសពីស.ភ.ភ.ព.ល្អមប្រើបាស់បាន | 0.69 |
| • ការសិក្សានៅស.ភ.ភ.ព.បានជួយឲ្យអ្នកមានសមត្ថភាពច្នៃប្រឌិត | 0.67 |
| • ចំណេះនិងជំនាញរបស់អ្នកអាចជួយអ្នកបង្កើតសហគ្រិនភាពផ្ទាល់ខ្លួន | 0.67 |
| • ការសិក្សានៅស.ភ.ភ.ពេបានជួយអ្នកឲ្យមានសមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័តមាន(ICT) | 0.65 |

Note: WAI = weight average index measured on a five-point scale [very less (VL) = 0.00–0.20, less (L) = 0.21–0.40, moderate (M) = 0.41–0.60, high (H) = 0.61–0.80, very high (VH) = 0.81–1.00]. OA = Overall assessment. Significance at the 0.05 level.

## ៣.១១ បំណងបន្តការសិក្សា

តាមទិន្នន័យគំរូតាងនិស្សិត(n=1133)ដែលបានបញ្ចប់ការសិក្សាបានបង្ហាញថា និស្សិត៧៦.២%មានបំណងចង់បន្តការសិក្សាបន្ថែមទៀត ប៉ុន្តែក្នុងចំណោមអ្នកទាំងមាននិស្សិតចំនួន៦៤.៥%ចង់បន្តការសិក្សាលើជំនាញដដែល ហើយចង់ចង់សិក្សាតាមបែបអារូបករណ៍៦.២% និងចំនួន១៤.៧% ចង់សិក្សាតាមរយៈបង់ថ្លៃ ដោយឡែកអ្នកដែល

ចង់បន្តការសិក្សានៅNIE ប្រមាណជា៣០% តែប៉ុណ្ណោះ។ តាមទិន្នន័យដែលបានបង្ហាញនេះ ឆ្លុះបញ្ចាំងឱ្យឃើញថា សាកលវិទ្យាល័យភូមិន្ទភ្នំពេញអាចមានឱកាសច្រើនក្នុងការពង្រីកកម្មវិធីសិក្សាដែលខ្ពស់ជាងកម្រិតបរិញ្ញាបត្រ។




ក្រាហ្វិក 16៖ គោលបំណងបន្តការសិក្សា

## ៤.សេចក្តីសន្និដ្ឋាន

តាមបេកគំហើញដែលវិភាគទិន្នន័យខាងលើ យើងអាចសន្និដ្ឋានបានថាកម្មវិធីសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញមានគុណភាពខ្ពស់ ហើយឆ្លើយតបនឹងតម្រូវការជំនាញទីផ្សារការងារនិងសង្គមកម្ពុជា។ តាមការវិភាគទិន្នន័យនិស្សិតដែលបញ្ចប់ការសិក្សាបានបង្ហាញថានិស្សិតភាគច្រើន(៦៤.៧%)មានអាជីពមួយច្បាស់ លាស់ ហើយ ចំណេះដឹង ជំនាញ និងគុណតម្លៃ ដែលពួកគេទទួលបានពីការសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញជាកត្តាដែលជួយដល់ការស្វែងរកនិងបំពេញការងារមួយយ៉ាងពិតប្រាកដ។ កត្តាដែលគួរឲ្យចំណាប់អារម្មណ៍គឺនិស្សិតដែលបានបញ្ចប់ថ្នាក់បរិញ្ញាបត្រចំនួន៨៧.៧%ទទួលបានការងារពេញម៉ោងក្នុងនោះ៧៧.៨%បានធ្វើការលើជំនាញដែលពួកគេបានសិក្សាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ដោយផ្អែកលើបេកគំហើញដែលបរិយាយពីខាងលើ យើងអាចទាញការសន្និដ្ឋានអំពីលទ្ធភាពស្វែងរកការងារធ្វើរបស់និស្សិតដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញដូចខាងក្រោម៖

- សាកលវិទ្យាល័យភូមិន្ទភ្នំពេញនៅតែជាកន្លែងបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយគុណភាពនិងសមត្ថភាព ជាទីទំនុកចិត្តសម្រាប់រួមចំណែកបង្កើនសមិទ្ធផលដល់សេដ្ឋកិច្ចសង្គម។
- និស្សិតដែលបានបញ្ចប់ការសិក្សាពីគ្រឹះស្ថានជាតិមួយនេះមានលទ្ធភាពនិងឱកាសច្រើនក្នុងការទទួលបានការងារមួយអចិន្ត្រៃយ៍ ក្រៅពីស្ថាប័នអប់រំ។
- ក្រៅពីបង្កើនសមត្ថភាពដល់អ្នកសិក្សាក្នុងបំណិនឯកទេស សាកលវិទ្យាល័យអាចផ្តល់បំណិនជីវិតខាងឥរិយាបថដែលជួយឲ្យនិស្សិតមានសមត្ថភាពទន់ភ្លន់ បត់បែន ចេះទទួលខុសត្រូវលើការងារ មានទំនុកចិត្តលើ

ខ្លួនឯង មានសមត្ថភាពដោះស្រាយបញ្ហារ ធ្វើការងារជាក្រុម មានគំនិតច្នៃប្រឌិត មានឆន្ទៈរៀនសូត្រ តស៊ូអត់ធ្មត់និងភាពជាអ្នកដឹកនាំ ដែលជាជំនាញទន់ក្នុងការបំពេញកិច្ចការងារដែលមិនអាចខ្វះបាន។

- បន្ថែមលើការផ្តល់ចំណេះដឹងនិងសមត្ថភាពដល់និស្សិតប្រកបដោយគុណភាព កម្មវិធីសិក្សារបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញមានលក្ខណៈស្តង់ដា ស្របទៅនឹងក្របខណ្ឌគុណវុឌ្ឍិជាតិ និងឆ្លើយតបនិងតម្រូវការទីផ្សារការងារ។

## ៤.១ អនុសាសន៍

ដោយផ្អែកទៅលើយន្តការវិភាគនិងប្រមូលទិន្នន័យ និងការចូលរួមផ្តល់ព័តមានពីអ្នកចូលរួមក្នុងការស្រាវជ្រាវនេះ យើងសូមផ្តល់អនុសាសន៍មួយចំនួនដូចខាងក្រោម៖

- គ្រឹះស្ថានត្រូវរៀបចំកែលម្អយន្តការផ្តល់សេវានិស្សិត ដូចជាផ្នែកការិយាល័យប្រឹក្សាការងារសេកភព សមាគមន៍និស្សិត និងការផ្សព្វផ្សាយព័ត៌មានការងារ
- ផ្តល់សេវាប្រឹក្សានិស្សិត និងរៀបចំការវាយតម្លៃកម្មវិធីសិក្សាឱ្យបានទៀងទាត់
- កសាងទំនាក់ទំនងល្អជាមួយបណ្តានិយោជកតាមស្ថាប័នឯកជន ឬក្រុមហ៊ុន ជាកន្លែងដែលអតីតនិស្សិតធ្លាប់ធ្វើការ ឬកំពុងធ្វើការ ដើម្បីសិក្សាអំពីការងារទីផ្សារស៊ីជម្រៅ
- ផ្តល់ឱកាសឱ្យនិស្សិតចុះកម្មសិក្សា ឬហាត់ការឱ្យបានច្រើនដើម្បីពួកគេមានបទពិសោធន៍ធ្វើការងារ
- បង្កើតសិក្ខាសាលាចែករំលែកបទពិសោធន៍ការងារ និងឱកាសការងារសម្រាប់និស្សិត
- ប្រមូលរក្សាទុកទិន្នន័យនិស្សិតគ្រប់ជំនាន់ដើម្បីសិក្សាពីប្រសិទ្ធភាពនិងប្រសិទ្ធផលលើធនធានដែលបានបណ្តុះបណ្តាល
- បន្តការសិក្សាស្រាវជ្រាវអំពីស្ថានភាពនិស្សិតក្រោយការបញ្ចប់ការសិក្សាឲ្យបានស៊ីជម្រៅ ពោលគឺមានភាគីនិយោជកដែលប្រើប្រាស់និស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មកចូលរួមផ្តល់ព័ត៌មាន ឬកម្មវិធីសិក្សានីមួយៗត្រូវធ្វើការសិក្សាបែបនេះដោយខ្លួនឯងជាបន្តទៀត
- ត្រូវសិក្សាបន្ថែមអំពីកម្រិតប្រាក់ខែនិងប្រភេទភារកិច្ចនិងតួនាទី និងស្វែងរកមូលហេតុប្រាក់បៀវត្សមានកម្រិតដោយត្រូវសិក្សាលើគំរូសំណាកនេះឡើងវិញនៅក្នុងរយៈពេល៥ឆ្នាំក្រោយ
- គម្បីកែលម្អកម្មវិធីសិក្សាឲ្យបានល្អដើម្បីទាក់ទាញចំណាប់អារម្មណ៍និស្សិត និងស្របតាមតម្រូវការការងារទីផ្សារបន្ថែមទៀត
- រក្សានិងពង្រឹងសមត្ថភាពនិស្សិតលើភាសាបរទេស ជាពិសេសភាសាអង់គ្លេស និងជំនាញទាក់ទងសតវត្សទី ២១ ដូចជា ជំនាញក្នុងការគិត ចំណេះដឹងច្នៃប្រឌិត សមត្ថភាពទំនាក់ទំនងនិង ធ្វើការងារជាក្រុម ចំណេះដឹងស្រាវជ្រាវនិងព័ត៌មាន សមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ឥរិយាបថបត់បែនទន់ភ្លន់ ភាពជាអ្នកដឹកនាំ ចំណេះដឹងក្នុងការផ្តួចផ្តើមគំនិតអភិវឌ្ឍន៍ ដែលជាផ្នែកសំខាន់ៗក្នុងក្របខណ្ឌគុណវុឌ្ឍិជាតិ។

ឧបសម្ព័ន្ធ១៖មតិបន្ថែមរបស់និស្សិត

ខាងក្រោមគឺជាទស្សនៈនិស្សិតទាំងស្រុងដោយគ្មានការបន្ថែមបន្ថយអត្ថន័យដើមឡើយ។ ក្នុងនោះមានទស្សនៈស្រដៀងគ្នាជាច្រើនដែលក្រុមនិស្សិតបានលើកឡើង ប៉ុន្តែក្រុមអ្នកស្រាវជ្រាវបានជ្រើសរើសយកតែមួយចំនួនដើម្បីកាត់បន្ថយន័យដដែលៗ។

## ការសិក្សានិងការងារ

- ខ្ញុំគិតថា ស.ភ.ភ.ព មានដេប៉ាតឺម៉ង់ច្រើនហើយជំនាញទាំងនោះក៏កំពុងរីកដុះដាលក្នុងទីផ្សារការងារបានមួយកម្រិត។
- គួរតែតម្រង់ទិសដៅជំនាញពីឆ្នាំទី៣ និងជួយរក ឬទាក់ទងក្រុមហ៊ុនដែលជាដៃគូដើម្បីអោយពួកគាត់ងាយស្រួលក្នុងការចុះកម្មសិក្សា។
- អាចមានឪកាសការងារទាំងក្នុងវិស័យផ្សេងៗបានច្រើន និងល្អប្រសើរ។
- អាចបន្ថយមុខវិជ្ជា ឬក៏បន្ថែមម៉ោងសិក្សា និងជួយពង្រឹងដល់និសិត្សឆ្នាំទី3,4 ដែលចង់ចាប់យកជំនាញណាមួយឲត្រូវទៅតាមទីផ្សារកាងារ។
- សម្រាប់ទំនាក់ទំនងរវាងការសិក្សាជាមួយគ្រូនឹងសិស្ស គឺមានភាពល្អប្រសើរ(ព្រោះគ្រូបើកអោយកូនសិស្សសួរតាមចិត្តរាល់ចម្ងល់ដែលទាក់ទងទៅនឹងខ្លឹមសារមេរៀន)។ ចំពោះតម្រូវការទីផ្សារវិញខ្ញុំគិតថាល្អ ត្រូវនឹងទីផ្សារការងារបច្ចុប្បន្ន ព្រោះនៅក្នុងប្រទេសគឺត្រូវការធនធានមនុស្សយ៉ាងខ្លាំងសម្រាប់ការអភិវឌ្ឍប្រទេស។ ដូច្នេះហើយទើបគ្រូបង្រៀន មានទីផ្សារខ្លាំងព្រោះប្រទេសយើងត្រូវការគ្រូដែលមានសម្ថភាពក្នុងការផ្តល់ចំណេះដឹង។
- ជួយសហការជាមួយកន្លែងការងារផ្សេងអោយបានច្រើនដើម្បីអោយសិស្សងាយស្រួលហាត់ការ និងទទួលបានកន្លែងការងារល្អត្រូវតាមជំនាញ។
- ការសិក្សាត្រូវផ្សារភ្ជាប់ជាមួយនឹងទិដ្ឋភាពសង្គម និងការងារជាក់ស្តែងនៅក្នុងម៉ោងសិក្សា ដើម្បីបណ្តុះគំនិតនិស្សិត។
- ការសិក្សាទៅលើជំនាញដាលខ្លួនចង់វាពិតជាមានសារៈសំខាន់ខ្លាំងនាពេលបច្ចុប្បន្ន។
- ទំនាក់ទំនងរវាងការសិក្សានៅស.ភ.ភ.ព ពិតជាមានទំនាក់ទំនងខ្លាំងណាស់ដែលជាតម្រូវការទីផ្សារកាងារកំពុងត្រូវការខ្លាំង។
- ទំនាក់ទំនងរវាងការសិក្សានិងតម្រូវការទីផ្សារកម្ពុជាបច្ចុប្បន្នវាល្អ។
- សាកលវិទ្យាល័យមានសឹងគ្រប់មុខដែលជាតម្រូវការទីផ្សារបច្ចុប្បន្ន។
- សម្រាប់តម្រូវការទីផ្សារការងារកម្ពុជាក្នុងពេលបច្ចុប្បន្ននេះ គឺពិតជាត្រូវការខ្លាំងណាស់សម្រាប់និស្សិតដែលមានភាពច្បាស់លាស់ក្នុងចំណេះជំនាញដែរខ្លួនបានសិក្សា ដើម្បីយកទៅប្រើការឲ្យល្អប្រសើរក្នុងការអនុវត្តការងារក្នុងពេលបច្ចុប្បន្ន ហើយការសិក្សានៅក្នុង ស.ភ.ភ.ព ក៏មានលក្ខណៈល្អប្រសើរខ្លាំងណាស់សម្រាប់និស្សិតទទួលបានចំណេះដឹងពិតប្រាកដយកទៅប្រើប្រាស់ក្នុងការបំពេញការងារប្រចាំថ្ងៃបានល្អ។

- In my opinion, all Majors in RUPP are good and really helpful to all students. Also, they are easy to find a part-time or full-time job. It is right for the market need. Thank you
- សិក្សានៅស.ភ.ភ.ពមានការងារច្រើននៅកម្ពុជា។
- ស.ភ.ភ.ព មានដេប៉ាតឺម៉ង់ច្រើនហើយជំនាញទាំងនោះក៏កំពុងរីកដុះដាលក្នុងទីផ្សារការងារបានមួយកម្រិត។
- ជំនាញដែលនាងខ្ញុំបានសិក្សាកន្លងមកវាពិតជាផ្តល់នៅសារៈប្រយោជន៍ជាច្រើនសម្រាប់ការងាររបស់ខ្ញុំសព្វថ្ងៃនេះដែលផ្សារភ្ជាប់ទ្រឹះស្តីទៅនិងការអនុវត្តន៍ វាជាគ្រឹះមួយដ៏សំខាន់សម្រាប់សង្គមបច្ចុប្បន្នដែរជួបប្រទះទៅនិងបញ្ហារជំងឺរាតត្បាតផ្សេងៗ។
- ទំនាក់ទំនងរវាងការសិក្សានៅស.ភ.ភ.ព ពិតជាមានទំនាក់ទំនងខ្លាំងណាស់ដែលជាតម្រូវការទីផ្សារកាងារកំពុងត្រូវការខ្លាំង។
- ស.ភ.ភ.ព ជាសាកលវិទ្យាល័យមួយដែលមានមុខជំនាញដែលល្អៗ និងសម្បូរទីផ្សារការងារក្នុងស្រុកជាច្រើន
- យើងសិក្សានៅ ស ភ ភ ព យើងអាចយកជំនាញដែរយើងបានសិក្សា យកមកអនុវត្តនៅជីវិតយើងបច្ចុប្បន្នដើម្បីសម្រួលដល់ការងាររបស់យើងផងដែរ។
- មុខជំនាញនីមួយៗក្នុងសាកលវិទ្យាល័យភូមិន្ទភ្នំពេញសុទ្ធតែសំខាន់ក្នុងការយកទៅអភិវឌ្ឍន៍ និងតម្រូវការទីផ្សារ។
- ក្រោយបញ្ចប់ការសិក្សានៅ ស.ភ.ភ.ព ខ្ញុំគិតថាធ្វើអោយនិស្សិតងាយរកការងារធ្វើ។
- ការសិក្សានៅ ស.ភ.ភ.ព. គឺធ្វើអោយនិស្សិតមានសមត្ថភាពក្នុងការប្រកួតប្រជែងទីផ្សារការងារនៅកម្ពុជានាពេលបច្ចុប្បន្ន។
- និស្សិតគួរតែរៀនផងធ្វើការផង ដើម្បីយកបទពិសោធន៍ប្រសិនបើគិតតែពីរៀនមិនខ្វល់ពីបទពិសោធន៍ការពេលចប់ទៅមានផលពិបាករឿងរកការងារធ្វើព្រោះគ្រប់គ្រឹះស្ថានគេត្រូវការអ្នកដែលមានបទពិសោធន៍ហើយសញ្ញាប័ត្រក៏សំខាន់។
- សាកលវិទ្យាល័យភូមិន្ទភ្នំពេញជាសាលាដែលបានផ្តល់ជាមួយការអប់រំខ្ពស់ និងឱកាសការងារផ្សេង ទាំងរដ្ឋនិងឯកជន។
- ជំនាញដែលរៀននៅសាលកវិទ្យាល័យភូមិន្ទភ្នំពេញ គឺត្រូវនិងតម្រូវការទីផ្សារការងារច្រើន។
- ការសិក្សានៅស.ភ.ភ.ព គឺអាចធ្វើអោយងាយស្រួលក្នុងការរកការងារធ្វើទៅតាមគ្រឹះស្ថានឯកជននានា បានទៅតាមជំនាញដែលយើងបានសិក្សា។
- ខ្ញុំគិតថាទំនាក់ទំនងរវាងការសិក្សានឹងតម្រូវការទីផ្សារការងារបច្ចុប្បន្នមានទំនាក់ទំនងយ៉ាងខ្លាំងក្នុងវិស័យការងារមួយនេះ ព្រោះវាបានបង្ហាញពីសមត្ថភាពក៏ដូចជាចំណេះដឹងដែលបានមកពីការសិក្សា ក៏ដូចជាការលុតដំលើចំណេះ និងគំនិត ដែលជាចំណុចសំខាន់ក្នុងវិស័យនេះស្របតាមការអប់រំក្នុងសតវត្សទី21។
- ជំនាញស្របនឹងការងារបច្ចុប្បន្ន ហើយជួយដល់ខ្ញុំច្រើនណាស់។
- ការសិក្សានៅ ស.ភ. ភ.ព បានពង្រឹងសមត្ថភាព និងមានទីផ្សារការងារសមរម្យ មានជំនាញក្នុងការងារ។
- ក្រោយបញ្ចប់ការសិក្សានៅ ស.ភ.ភ.ព ពិតជាងាយស្រួលក្នុងការរកការងារធ្វើនៅតាមគ្រឹះស្ថានអប់រំ(ឯកជន)។

- ចំពោះបច្ចុប្បន្នខ្ញុំយល់ឃើញថា មុខវិជ្ជាដែលខ្ញុំបានរៀននៅស.ភ.ភ.ពគឺវាបានផ្សារភ្ជាប់យ៉ាងខ្លាំងនៅពេលបច្ចុប្បន្នព្រោះវាអាចជួយដល់មនុស្សជាច្រើននៅក្នុងសង្គមនិងថែមទាំងអាចជួយដល់កុមារដែរមានបញ្ហាទំនាក់ទំនងសង្គមថែមទៀតផង។
- ខ្ញុំគិតថា ការសិក្សាសំខាន់ណាស់លើផ្នែកស្រាវជ្រាវ ព្រោះការស្រាវជ្រាវ សរសេរសារណា និក្ខេបបទក្ដីនេះអាចឱ្យនិស្សិតមានចំណេះដឹងកាន់តែជ្រៅជ្រះ និងមានសមត្ថភាពកាន់តែខ្លាំង ដូចនេះការងារនឹងមានភាពងាយស្រួលក្នុងការស្វែងរកព្រោះមានជំនាញច្បាស់លាស់។
- ខ្ញុំសប្បាយចិត្តដែលបានរៀននៅស.ភ.ភ.ពព្រោះមុខវិជ្ជាដែលរៀនត្រូវនឹងទីផ្សារការងារនៅប្រទេសកម្ពុជា។

## ការពេញចិត្តរបស់និស្សិត

- សម្រាប់ទំនាក់ទំនងរវាងការសិក្សាជាមួយគ្រូនិងសិស្សគឺមានភាពល្អប្រសើរ(ព្រោះគ្រូបើកអោយកូនសិស្សសួរតាមចិត្តរាល់ចម្ងល់ដែលទាក់ទងទៅនឹងខ្លឹមសារមេរៀន)។ ចំពោះតម្រូវការទីផ្សារវិញខ្ញុំគិតថាល្អ ត្រូវនឹងទីផ្សារការងារបច្ចុប្បន្ន ព្រោះនៅក្នុងប្រទេសគឺត្រូវការធនធានមនុស្សយ៉ាងខ្លាំងសម្រាប់ការអភិវឌ្ឍប្រទេស។ ដូច្នេះហើយទើបគ្រូបង្រៀន មានទីផ្សារខ្លាំងព្រោះប្រទេសយើងត្រូវការគ្រូដែលមានសម្ថភាពក្នុងការផ្ដល់ចំណេះដឹង។
- ចំពោះខ្ញុំបានសិក្សានៅ ស.ភ.ភ.ព. រយៈពេល៤ឆ្នាំកន្លងមកទទួលបានបទពិសោធន៍ល្អៗ ជំនាញច្បាស់លាស់ ហើយលោកគ្រូអ្នកគ្រូ មានបទពិសោធន៍ខ្ពស់ៗ នេះមានទំនាក់ល្អជាមួយមជ្ឈដ្ឋានខាងក្រៅ។ សូមអរគុណ ស ភ.ភ.ព យ៉ាងខ្លាំង ។
- សូមអគុណលោកគ្រូ អ្នកគ្រូដែលបានយកចិត្តទុកដាក់ក្នុងការបង្រៀននឹងធ្វើអោយខ្ញុំ មានបទពិសោធន៍។
- ចំពោះខ្ញុំមិនមានអ្វីច្រើនទេ គឺមានតែអរគុណលោកគ្រូអ្នកគ្រូ ដែលបានយកចិត្តទុកដាក់បង្រៀននិងផ្ដល់ចំណេះដឹងដល់និស្សិតគ្រប់រូប ទោះក្នុងកាលៈទេសៈណាក៏ដោយ(បរិបទ COVID-19)។សូមអរគុណ
- ល្អសម្រាប់សិស្សនិស្សិតដែរបញ្ចប់ថ្នាក់បរិញ្ញាបត្រមានឱកាសធ្វើការបានគ្រប់គ្រាន់សម្រាប់បានប្រាក់ចំណូលផ្គត់ផ្គង់ប្រចាំខែ។
- RUPP is best university and about the subjects for study it focus on working.
- ជាដំបូងនាងខ្ញុំសូមថ្លែងអំណរអរគុណដល់លោកគ្រូអ្នកគ្រូនៅ ស.ភ.ភ.ព ដែលបានបង្ហាត់បង្រៀននាងខ្ញុំ(ជាពិសេសលោកគ្រូអ្នកគ្រូ ដេប៉ាតឺម៉ង់គីមី) ហើយក៏សូមជូនពរលោកគ្រូអ្នកគ្រូនៅ ស.ភ.ភ.ព មានសុខភាពល្អកម្លាំងមាំមួន។
- រាល់មុខជំនាញទាំងអស់សុទ្ធតែមានគុណភាពខ្ពស់ក្នុងចំណោមវិស័យអប់រំនៅក្នុងស.ភ.ភ.ព.ក៏ដូចជាក្នុងប្រទេសផងដែរ។ ការជ្រើសរើសជំនាញដែលអ្នកពេញចិត្តអ្នកនឹងរីករាយក្នុងការសិក្សា ហើយសម្លឹងឲ្យឆ្ងាយពីមុខជំនាញដែលអ្នកនឹងរើស។
- បានផ្ដល់ចំណេះដឹងទូលំទូលាយដល់និស្សិតដែលអាចផ្សារភ្ជាប់ទៅនឹងតម្រូវការការងារសង្គមបានច្រើន។
- ប្រព័ន្ធអប់រំវិន័យ និងឱកាសការងារទូលំទូលាយ។
- មុខជំនាញនីមួយៗក្នុងសាកលវិទ្យាល័យភូមិន្ទភ្នំពេញសុទ្ធតែសំខាន់ក្នុងការយកទៅអភិវឌ្ឍន៍ និងតម្រូវការទីផ្សារ។

- ក្រោយបញ្ចប់ការសិក្សានៅ ស.ភ.ភ.ព ខ្ញុំគិតថាធ្វើអោយនិស្សិតងាយរកការងារធ្វើ។
- សម្រាប់ខ្ញុំផ្ទាល់ ស.ភ.ភ.ព ផ្តល់ទាំងចំណេះ និងជំនាញព្រមទាំងបទពិសោធន៍ខ្លះៗ។
- All skills I′ve learnt can lead to the careers that I′ve been doing now; especially the communication and motivation skills can make me to be confident to go out and find job. Before I found my currently job, I have connected to many of my friends and successfully found it. That′s all come from I have learnt from my study.
- There are many important subjects but some subjects require lecturers who are skillfull in transferring the knowledge and skills. The studies are based on theory rather than theory-practice. Some lessons are not related to Cambodian marketing. Most student only know the theory but have never practice them. So having a practicum curriculum would be beneficial for them namely 3-month internship as a assessment before graduation.

## មតិយោបល់របស់និស្សិត

- មានជំនាញផ្តល់អោយសិស្សល្អហើយ ប៉ុន្តែសាលានៅខ្វះខាតសម្ភារះពិសោធគ្រប់គ្រាន់សម្រាប់សិក្សា សិស្ស មិនសូវមានការអនុវត្តបានច្រើន មានតែទ្រឹស្តី សិស្សទទួលបានពត៌មានតិចក្នុងការសហរវែងរកការចុះកម្ម សិក្សាទីផ្សារចង្អៀតក្នុងការរកកម្មសិក្សា។
- ក្រោយពីបញ្ចប់ការសិក្សានៅស.ភ.ភ.ព.តម្រូវការក្នុងការទទួលបានការងារដែលត្រូវជំនាញមានភាគរយតិច ណាស់ហើយតម្រូវការងារមានការប្រកួតប្រជែងខ្លាំង។
- បានផ្តល់ចំណេះដឹងទូលំទូលាយដល់និស្សិតដែលអាចផ្សារភ្ជាប់ទៅនឹងតម្រូវការការងារសង្គមបានច្រើន។
- ចំពោះជំនាញ Bio-Engineering ដោយសារទើបបង្កើតថ្មី ដូចនេះតម្រូវការទីផ្សារការងារចង្អៀតដែលមាន ផលវិបាកដល់និស្សិតមួយចំនួនដែលមានការពិបាកក្នុងការស្វែងរកការងារធ្វើ សូមខាងសាលាជួយស្វែងរក ក្រុមហ៊ុនដែលជាស្ថាប័នពាក់ព័ន្ធនិងការងារសម្រាប់និស្សិតផង។
- ចំពោះខ្ញុំមានការពិបាកដោយសារតែខ្ញុំទៅដាក់ពាក្យធ្វើការដើម្បីចង់បានបទពិសោធន៍ ប៉ុន្តែខាងក្រុមហ៊ុនឬ ខាងណាក៏ដោយតែងនិយាយថាទាល់មានបទពិសោធន៍ទើបអោយធ្វើ សួរថាតើខ្ញុំមានបទពិសោធន៍មកពី ណា ?
- តម្រូវឲ្យត្រូវតែចេះមុខជំនាញនឹងភាសាអង់គ្លេសច្បាស់។
- អ្វីដែលខ្ញុំគិតការសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ជំនាញខ្លះឆ្លើយតបទៅនឹងទីផ្សារការងារក្នុងស្រុក ខ្លាំងមែនទែន។ តែជំនាញខ្លះពិតជាចង្អៀតធ្វើឲ្យនិស្សិតពិបាករកការងារធ្វើបន្ទាប់ពីបញ្ចប់ការសិក្សា ។ ជំនាញ

មួយចំនួនកម្រិតបរិមាណសិស្សដែលអាចចូលរៀនបាន តែជំនាញខ្លះគឺមិនបានកំណត់ទេ ដែលមួយថ្នាក់មានច្រើននាក់ដែលធ្វើឲ្យគុណភាពអប់រំនៅមានកម្រិត។

- ក្រោយពីបញ្ចប់ការសិក្សាសង្កេតឃើញសាលាមានទំនាក់ទំនងច្រើនជាមួយក្រុមហ៊ុននិងផ្ដល់អាហារូបករណ៍ដល់សិស្ស ប៉ុន្តែសម្រាប់សិស្សមុខវិជ្ជាគណិតស្ថិតិនៅមានកម្រិតតិចតួចណាស់ ព្រោះមុខវិជ្ជានេះថ្មីត្រូវបង្កើនឱកាសសម្រាប់សិស្សអោយបានច្រើននិងពត៌មានផ្សេង ត្រូវបើកពត៌មានទាក់ទងនឹងការងារសមស្រមនឹងជំនាញនេះអោយទូលំទូលាយជាងនេះព្រោះមុខវិជ្ជានេះថ្មីសិស្សមិនសូវបានពត៌មានគ្រប់គ្រាន់តម្រូវទិសដៅការងារនិងការសិក្សារបស់ពួកគេទេ។
- ចំពោះទំនាក់ទំនងរវាងការសិក្សានៅ RUPP គឺមានលក្ខណៈល្អប្រសើរ ទាំងគ្រូ ទាំងសិស្ស។ ប៉ុន្តែក៏នៅមានចំណុចខ្វះខាតមួយចំនួនផងដែរ ដូចជាសម្ភារៈពិសោធន៍ជាដើម មិនទាន់មានឧបករណ៍គ្រប់គ្រាន់100%នៅឡើយ។ សម្រាប់តម្រូវការទីផ្សារការងារវិញ គឺពិតជាល្អខ្លាំងណាស់ ព្រោះទាំងសាលារដ្ឋ និងសាលាឯកជនគឺត្រូវការគ្រូខ្លាំងណាស់។
- គណិតវិទ្យាជាមុខវិជ្ជាមានតម្រូវការខ្ពស់ និងអាចបត់បែនប្រើប្រាស់បានច្រើនវិស័យ ប៉ុន្តែការសិក្សាបច្ចុប្បន្នខ្វះការអនុវត្ត ផ្សាភ្ជាប់បច្ចេកវិទ្យា រួមជាមួយនឹងការផ្ដោតទៅឲ្យបានជាក់លាក់ជាមួយការងារតម្រង់ទិសទៅតាមផ្នែកតែម្ដង វាមានលក្ខណៈទូទៅនៅឡើយ។
- ខ្ញុំពិតជាអរគុណខ្លាំងណាស់ដល់លោកគ្រូអ្នកគ្រូដែលបានខិតខំបង្រៀនកូនៗបានយ៉ាងល្អ។
- ខ្ញុំគ្រាន់តែចង់បន្ថែមនៅចំនុចតូចមួយ គឺទាក់ទងនឹងជំនាញនៃការស្រាវជ្រាវ និងទំនាក់ទំនងគឺតែមានការរឹតបន្តឹងបន្ថែមទៀតគឺកាន់តែល្អប្រសើរឡើង និងងាយស្រួលប្រសិនបើយើងចេះតែទ្រឹស្ដី តែការអនុវត្តនៅស្ទើក៏រៀងពិបាកដែរនៅពេលដែលរៀនចប់ ហើយចង់រកការងារធ្វើ។

## សំណូមពរនិស្សិត

- ស.ភ.ភ.ពគួតែតម្រង់ទិសដៅជំនាញពីឆ្នាំទី៣និងជួយរកឬទាក់ទងក្រុមហ៊ុនដែលជាដៃគូដើម្បីអោយពួកគាត់ងាយស្រួលក្នុងការចុះកម្មសិក្សា។
- សិស្សខ្លះមិនសូវប្រឹងទេបើលោកគ្រូមិនដាក់ពិន័យ ដូច្នេះត្រូវដាក់ការងារឲ្យច្រើន និងពិន័យចំពោះនិសិត្យដែរពុំបានធ្វើ។
- បង្កើតទំនាក់ទំនងនឹងសហការជាមួយក្រុមហ៊ុនឯកជនឲច្រើន ដើម្បីបង្កើតឱកាសការងារដល់និស្សិតនឹងកម្មវិធីទស្សនៈកិច្ចជាមួយក្រុមហ៊ុនផ្សេងៗ ឲនិស្សិតស្វែងយល់ពីងាការ។
- នាងខ្ញុំ សូមធ្វើការបញ្ចេញមតិទៅកម្មវិធីសិក្សានៅ ស.ភ.ភ.ព អោយមានការពង្រឹងបន្ថែមទៀតចំពោះកម្មវិធីសិក្សា និងការអនុវត្តជាក់ស្តែងដល់និស្សិត។
- I would like to request that my department provide the student with both theoretical and practical training in the specific technical skills. Furthermore, student should join internships program for year 3 to gain experience for a future job.
- ខ្ញុំចង់អោយការសិក្សាក្នុងសាលាបង្រៀនអោយស៊ីជម្រៅទាក់ទងនឹងជំនាញណាមួយដែលសិស្សនិស្សិតរៀនអោយបានច្បាស់នឹងប្រើប្រាស់បានត្រូវ។ សាលាគួរមានអ្នកចង្អុលបង្ហាញពីការចុះកម្មសិក្សាតាមជំនាញអោយ

បានទូលំទូលាយ។ ម្យ៉ាងទៀតទាក់ទងនឹងទំនាក់ទំនងការសិក្សាមួយការងារអោយសិស្សនិស្សិតស្គាល់ជំនាញច្បាស់ដែលអាចងាយស្រួលនឹងយល់ពីការងារត្រូវជំនាញពួកគេ។

- សូមជួយបន្ថែមការអនុវត្តផ្ទាល់ឲ្យបានច្រើន និងជួយរកការងារដល់និស្សិតដែលបានបញ្ចប់ការសិក្សានៅ Rupp។
- Only knowledge from school isn't enough. School should put a short program training for students and let them experiences the process of working. They could improve a lot from that and have a lot of experiences. It just like the progress of learning and growing.
- សូមឲ្យខាងសាលាផ្តល់ពត៌មានឲ្យបានច្រើនពីការងារដែលទាក់ទងនឹងជំនាញៗនីមួយៗដើម្បីឲ្យនិស្សិតដែលកំពុងរៀននិងបញ្ចប់ការសិក្សារងាយស្រួលរកការងារធ្វើ,យកចិត្តទុកដាក់បន្ថែមលើកិច្ចការនិស្សិត, ជូនចំណេះដឹងថ្មីៗដល់និស្សិត។
- ខ្ញុំចង់អោយប្អូនៗជំនាន់ក្រោយរៀនបណ្តើរធ្វើការបណ្តើរជាមួយសាលាផ្ទាល់ឬស្ថាប័នណាមួយដើម្បីបានបទពិសោធន៍ងាយស្រួលរកការងារធ្វើពេលរៀនចប់។
- ខ្ញុំចង់អោយសាលាហាត់ការ និងបណ្តាលក្រុមហ៊ុនផ្សេងដើម្បីអោយសិស្សនិស្សិតរឹតតែទទួលបានឱកាសការងារ ហើយនិងបង្កើតគុណភាពបន្តទៀត។
- សូមជួយសហការជាមួយកន្លែងការងារផ្សេងអោយបានច្រើនដើម្បីអោយសិស្សងាយស្រួលហាត់ការ និងទទួលបានកន្លែងការងារល្អត្រូវតាមជំនាញ។
- ក្នុងកំឡុងពេលក្នុងការចុះកម្មសិក្សារបស់និស្សិតឆ្នាំទី4 សុំខាងសាលាមេត្តាជួយរកកន្លែងអោយនិស្សិតចុះកម្មសិក្សាផង ឬធ្វើការសហការជាមួយក្រុមហ៊ុនផ្សេងៗ និងសុំអោយមានការកំណត់ថ្ងៃច្បាស់ក្នុងការការពារបញ្ចប់និងប្រលង ដើម្បីអោយនិស្សិតមានការត្រៀមខ្លួន និងរៀបចំទាន់ សុំអោយបានមុន3ខែមុនមក។
- សូមអោយមានឧបករណ៍គ្រប់គ្រាន់ប្រើប្រាស់នៅមន្ទីរពិសោធន៍។
- ការសិក្សារល្អ ប៉ុន្តែចង់ឲ្យមានការអនុវត្តបានច្រើនដូចជាការប្រើប្រាស់ពួកម៉ាស៊ីនធំៗទាក់ទងនឹងchemical
- ខ្ញុំចង់អោយខាង ស.ភ.ភ.ព ផ្តោតទៅលើការបង្រៀននូវមុខវិជ្ជាដែលមានតម្រូវការទីផ្សារការងារអោយបានច្រើនជាងនេះបន្ថែមទៀត ដើម្បីអោយនិស្សិតដែលបានបញ្ចាប់ការសិក្សាមានឧកាសក្នុងការរកការងារ។
- ស.ភ.ភ.ព គួរតម្រង់ទិសដៅការងារដល់និស្សិត តាមដេប៉ាតឺម៉ង់នីមួយៗ ជាពិសេសការហាត់ការ សម្រាប់ការងារក្នុង
- រយះពេលខ្លីដើម្បីអោយនិស្សិតបានត្រៀមខ្លួនចាប់យកឱកាសការងារក្រោយបញ្ចប់ការសិក្សា។
- សុំសាស្ត្រចារ្យមានទំនាក់ទំនងអោយបានច្រើនតាមបណ្តាលក្រុមហ៊ុនផ្សេងៗដែពាក់ព័ន្ធនឹងមុខជំនាញដើម្បីអោយសិស្សងាយស្រួលក្នុងការស្វែងរកឱកាសការងារ។
- សាលាមានបច្ចេកទេសបង្រៀនល្អ និងមុខវិជ្ជាថ្មីៗនិងកាផ្សព្វផ្សាយមានភាពមម៉ាញឹក ប៉ុន្តែក្នុងនាមខ្ញុំផ្ទាល់ឃើញថាពេលពួកយើងព្យាយាមចុះកម្មសិក្សាមានក្រុមហ៊ុនជាច្រើនដែលមិនស្គាល់ និងយល់ពីជំនាយពួកយើងបានសិក្សា ក្នុងន័យនេះខ្ញុំគ្រាន់តែចង់អោយសាលាមាន Community ជាមួយក្រុមហ៊ុនឯកជនធំៗអោយបានច្រើន រឺដឹកនាំសិស្សបានចុះស្គាល់នៅទីតាំងដំណើរការរបស់ក្រុមហ៊ុន ហេតុនេះវាងាយស្រួលបន្ថែមអោយសិស្សទាងអស់ងាយស្រួលចូលធ្វើការក៏ដូចសិក្សាបន្ថែមពីរឿងនេះ។

- សូមអោយខាងការិយាល័យសិក្សាប្រើភាសាសមរម្យនិងទន់ភ្លន់ដាក់សិស្សានុសិស្ស។
- សម្រាប់ខ្ញុំមានមតិបន្តិចបន្តួច គួរលើកទឹកចិត្តនិស្សិតក្នុងការស្វែងរកការងារឱ្យពួកគេអំឡុងពេលសិក្សា (ហាត់ការណ៍) ដើម្បីមានឱកាសយកបទពិសោធន៍សម្រាប់បន្តក្រោយបញ្ចប់ឆ្នាំសិក្សានៅសកលវិទ្យាល័យ និងម្យ៉ាងវិញទៀតគួរតែលើកកម្ពស់តម្លៃនិស្សិតក្រោយបញ្ចប់។
- សូមរៀបចំបន្ថែមនូវ បណ្ណាគំនិតបរិស្ថានល្អ បន្ទប់ទឹកស្អាត ឧបករណ៍សិក្សានិងពិសោធន៍គ្រប់គ្រាន់តាមបែបវិទ្យាសាស្ត្រ សណ្តាប់ធ្នាប់ក្នុងសាលា...។ ល។
- ខ្ញុំគិតនៅស.ភ.ភ.ព.គួរណាបន្ថែមនូវមុខមួយចំនួនទៀតដែលទីផ្សារនៅកម្ពុជាកំពុងតែត្រូវការដូចជាមុខវិជ្ជាវិស្វករ ឬវិស្វកម្មជាដើម។
- សូមមានមតិដូចជាការស្នើសុំអោយស.ភ.ភ.ព ពង្រឹងបន្ថែមលើការអប់រំទាំងទ្រឹស្តី និងការអនុវត្តន៍អោយកាន់តែល្អប្រសើរថែមទៀតដើម្បីជួយដល់និស្សិតអោយមានភាពងាយស្រួលក្នុងរកការងារដែលត្រូវនឹងជំនាញរៀងៗខ្លួន។សូមអរគុណ!
- ចង់អោយសាលាបង្កើតបន្ទប់ពិសោធន៍ព្រមទាំងមានសម្ភារៈថ្មីៗច្រើន។ មួយវិញទៀតសាលាគួរមានទំនាក់ទំនងក្នុងការបញ្ជូនសិស្សទៅចុះកម្មសិក្សាអោយបានច្រើនក្នុងការទទួលបានបទពិសោធន៍ពីខាងក្រៅដើម្បីពង្រឹងចំណេះដឹងនិងការអនុវត្តបានច្រើន។
- នាងខ្ញុំសូមពរឲ្យខាងស.ភ.ភ.ព ជួយទាក់ទងខាងក្រុមហ៊ុនឬស្ថាប័ននានាសម្រាប់និស្សិត Internship ឲ្យបានច្រើន។
- សូមអោយស.ភ.ភ.ព ជួយផ្សព្វផ្សាយទីផ្សារការងារដល់និស្សិតអោយបានច្រើនជាងមុន។
- សូមបង្កើនភាសាអង់គ្លេសនិងចង់ឲ្យមានជំនាញច្រើនជាងមុន។
- ខ្ញុំចង់អោយសាលាធ្វើការupdate កម្មវិធីសិក្សាដូចជា មុខវិជ្ជា web គួរតែចាប់ផ្តើមនៅឆ្នាំទី2 មិនមែនឆ្នាំទី4ទេព្រោះអាចយឺតជាងតម្រូវការទីផ្សារ។
- ខ្ញុំសុំអោយ ស.ភ.ភ.ព ផ្តោតលើភាសាអង់គ្លេសសម្រាប់និស្សិតអោយខ្លាំងជាងនេះ។
- ចំនួននិស្សិតមានច្រើន តែតម្រូវការជ្រើសរើសមន្ត្រីមានតិច។ សូមសំណូមពរ បន្ថែមការជ្រើសរើសធនធានមនុស្សបម្រើការងារអោយបានច្រើន។
- សូមពង្រឹងជំនាញឯកទេស និងបង្កើនការសិក្សាភាសាអង់គ្លេស។
- តាមមតិរបស់ខ្ញុំចង់ស្នើសុំអោយសាលាមានបើកវគ្គរៀនសិក្សាគរុកោសល្យ សម្រាប់គ្រូបង្រៀន។
- ខ្ញុំចង់អោយមានការសិក្សាដោយមិនរៀនតែទ្រឹស្តី ចង់បានការសិក្សាដែលផ្សាភ្ជាប់ជាមួយលំហាត់អនុវត្តដែលទាក់ទងគ្នាជាមួយកម្មវិធីសិក្សាទី12 ដែលមានទីផ្សាក្នុងសង្គមបច្ចុប្បន្ន។ ជាពិសេសខ្ញុំចង់អោយសាលាជួយក្នុងការកាត់បន្ថយចំពោះនិស្សិត លើការប្រើប្រាស់ផ្លាស្ទិចដែលបច្ចុប្បន្នច្រើនខ្លាំងដែលនិស្សិតប្រើប្រាស់ក្នុងមួយថ្ងៃៗ។ ជាចុងបញ្ចប់សូមអគុណលោកគ្រូ អ្នកគ្រូ សូមជូនពរសុខភាពល្អ។
- ចំពោះមតិរបស់ខ្ញុំ គ្រាន់តែចង់អោយសាលាបញ្ជាក់អំពីទីផ្សារការងារនៃមុខជំនាញនីមួយៗ ដើម្បីអោយនិស្សិតបានយល់កាន់តែច្បាស់។ ដូចជាការសិក្សារលើគណិតវិទ្យាបន្ទាប់ពីនិស្សិតបញ្ចប់ការសិក្សារតើពួកគាត់អាចប្រកបការងារអ្វីខ្លះក្រៅពីស្ថាប័នរដ្ឋ។សូមអរគុណ

- ការសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ គឺសំខាន់ណាស់សម្រាប់មនុស្សគ្រប់រូបដែលមានការចូលរួមចំណែកយ៉ាងសកម្មក្នុងតម្រូវការការងារនៅកម្ពុជាបច្ចុប្បន្ន។ ហេតុនេះហើយចំពោះនិស្សិតដែរចង់បានឳកាសការងារល្អត្រូវតែខិតខំសិក្សាលើជំនាញរបស់ខ្លួន និងសូមសាលាបន្ថែមការសិក្សាអំពីតម្រូវការការងារបទពិសោធន៍កាន់តែច្រើនថែមទៀតដើម្បីបង្កើតនូវប្រព័ន្ធការនៅកម្ពុជាបច្ចុប្បន្នឲកាន់តែច្រើន។ សូមអរគុណ
- ទំនាក់ទំងរវាងការសិក្សាជាមួយនឹងទីផ្សារការងារល្អហើយ ក៏ប៉ុន្តែការងារសុទ្ធតែចង់បានអ្នកដែលមានបទពិសោធន៍ច្រើនក្នុងការធ្វើការងារបាន ដោយឡែកចំពោះនិស្សិតដែលខ្វះខាតបទពិសោធន៍ការងារមានតែចំណេះ នៅតែពិបាកដដែល។
- បង្កើតទំនាក់ទំនងរវាងនិស្សិតគ្រប់បណ្តាដេប៉ាតឺម៉ង់ក្នុងការផ្លាស់ប្តូរការសិក្សា និងធ្វើគម្រោងនានា។ ការបង្កើតទំនាក់ទំនងរវាងនិស្សិតឆ្នាំខុសគ្នា ក្នុងដេប៉ាតឺម៉ងដូចគ្នា ដើម្បីទទួលបានការចែករំលែកបទពិសោធន៍ និងបង្កើត Networking បន្ទាប់ពីបញ្ចប់ការសិក្សាតាមរយៈការធ្វើគម្រោងជាមួយគ្នា។
- សម្រាប់ខ្ញុំសាលាគួរតែ បន្ថែមមុខវិជ្ជាទាក់ទងនឹងវិទ្យាសាស្ត្រកុំព្យូទ័រសម្រាប់អក្សរសាស្ត្រខ្មែរ។ អក្សរសិល្ប៍ឥណ្ឌាគួរតែកាត់ចេញអក្សរសិល្ប៍បច្ចឹមប្រទេសក៏មិនសូវមានប្រយោជន៍ដល់អ្នករៀនអក្សរសាស្ត្រខ្មែរដែរសាលាគួរតែសិក្សាទៅលើវេយ្យាករណ៍ខ្មែរអោយបានច្រើន។
- សូមអោយគ្រប់ដេប៉ាតឺម៉ង់ទាំងអស់ បញ្ចូលនូវមុខវិជ្ជាណាដែលសំខាន់ៗ និងមានប្រយោជន៍សម្រាប់តម្រូវការទីផ្សារកាងារបច្ចុប្បន្នអោយបានច្រើន។
- ចង់អោយការសិក្សាក្នុងសាលាបង្រៀនអោយស៊ីជម្រៅទាក់ទងនឹងជំនាញណាមួយដែលសិស្សនិស្សិតរៀនអោយបានច្បាស់នឹងប្រើប្រាស់បានត្រូវ។ សាលាគួរមានអ្នកចង្អុលបង្ហាញពីការចុះកម្មសិក្សាតាមជំនាញអោយបានទូលំទូលាយ។ ម្យ៉ាងទៀតទាក់ទងនឹងទំនាក់ទំនងការសិក្សាមួយការងារអោយសិស្សនិស្សិតស្គាល់ជំនាញច្បាស់ដែលអាចងាយស្រួលនឹងយល់ពីការងារត្រូវជំនាញពួកគេ។
- Only knowledge from school isn't enough. School should put a short program training for students and let them experiences the process of working. They could improve a lot from that and have a lot of experiences. It just like the progress of learning and growing.
- គួរតែផ្តល់ពត៌មានអោយបានច្រើនទាក់ទងនឹងឳកាសការងារ។
- ចង់អោយសាលាផ្តោតសំខាន់ទៅលើតែមុខវិជ្ជាដែល យើងរើសជំនាញអោយច្រើនជាងមុខវិជ្ជាផ្សេងៗ។
- សូមឲ្យខាងសាលាផ្តល់ព័ត៌មានឲ្យបានច្រើនពីការងារដែលទាក់ទងនឹងជំនាញៗនីមួយៗដើម្បីឲ្យនិស្សិតដែលកំពុងរៀននិងបញ្ចប់ការសិក្សារងាយស្រួលរកការងារធ្វើ,យកចិត្តទុកដាក់បន្ថែមលើកិច្ចការនិស្សិត, ជូនចំណេះដឹងថ្មីៗដល់និស្សិត។
- ឆមាសចុងក្រោយនៃឆ្នាំចុងក្រោយនៃការសិក្សា សូមឲ្យសាកលវិទ្យាល័យជួយបង្រៀនមេរៀនដែលអាចឲ្យសិស្សមានសមត្ថភាពអាចប្រឡងបាន ទាក់ទងនឹងការប្រឡងចូលក្របខ័ណ្ឌផ្សេងៗព្រោះថាកន្លងមកក្រោយបញ្ចប់សិស្សត្រូវត្រៀមប្រឡងទៀត។
- ចង់អោយសាលាមានការហាត់ការ និងបណ្តាលក្រុមហ៊ុនផ្សេងដើម្បីអោយសិស្សនិស្សិតរឹតតែទទួលបានឳកាសការងារ ហើយនិងបង្កើតគុណភាពបន្តរទៀត។

- សូមជួយបង្កើតទំនាក់ទំនងជាមួយនឹងក្រុមហ៊ុនឯកជនឲ្យច្រើន ដើម្បីបង្កើតឱកាសការងារដល់និស្សិតនឹងកម្មវិធីទស្សនៈកិច្ចជាមួយក្រុមហ៊ុនផ្សេងៗ ឲ្យនិស្សិតស្វែងយល់ពីការងារ។
- ខ្ញុំចង់អោយលោកគ្រូ អ្នកគ្រូ យកចិត្តទុកដាក់ចំពោះសិស្សានុសិស្សអោយបានគ្រប់ៗគ្នា។
- នាងខ្ញុំ សូមធ្វើការបញ្ចេញមតិទៅកម្មវិធីសិក្សានៅ ស.ភ.ភ.ព អោយមានការពង្រឹងបន្ថែមទៀតចំពោះកម្មវិធីសិក្សា និងការអនុវត្តជាក់ស្តែងដល់និស្សិត។
- សូមអោយខាងសាលាជួយរកទីផ្សាការងារអោយសិស្សនិស្សិត ហើយបង្រៀនអោយត្រូវនិងទីផ្សាកាងារ។ និងចង់អោយក្រសួងអប់រំសហការណ៍ជាមួយនឹងក្រសួងកាងារដើម្បីជួយបង្កើតទីផ្សារការងារអោយបានល្អជាងនេះ។
- សម្រាប់ខ្ញុំ ខ្ញុំបានសិក្សានៅRoyal university Phnom Penh ផ្នែកInternational Business Management នឹងនៅ Septic institute ផ្នែកManagement Information System ( IT ) ក្នុងឆ្នាំតែមួយ។ បង្កើនសម្ថតិភាពក្នុងការគ្រប់គ្រង់នឹងយល់ដឹងពីបច្ចេកវិទ្យាច្បាស់។ ងាយក្នុងការស្វែករកការងារធ្វើក្នុងពេលបច្ចុប្បន្ននឹង អនាគត។ ជាចុងក្រោយចង់ប្អូនៗដែលខ្សោយភាសាអង់គ្លេសប្រឹងប្រែង។ រយះពេលបួនឆ្នាំគួរតែគ្រប់គ្រាន់និយាយបានសសេរបាន។
- សម្រាប់ខ្ញុំដែលជានិស្សិតធ្លាប់បានឆ្លងកាត់ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាប័ត្រនា ស.ភ.ភ.ព ចង់អោយសាលាបន្ថែមនៅការផ្តល់ឱកាសដល់សិស្សជំនាន់ក្រោយក្នុងការទទួលបាននូវចេញទៅហាត់ការងារនៅតាមបណ្តាក្រុមហ៊ុនឬស្ថានប័ននានាជាច្រើនដែលជាដៃគូសហការណ៍ជាមួយសាលាដើម្បីធ្វើអោយសិស្សនិស្សិតទទួលបានបទពិសោធន៍ការងារក៏ដូចជាយល់ដឹងបន្ថែមពី Soft Skill របស់ខ្លួនដែលបានសិក្សាទៅតាមទ្រឹស្តីផ្សេងៗតាមមុខវិជ្ជារៀននៅក្នុងសាលា។
- សូមសាកលវិទ្យាល័យផ្តល់ឱកាសឲ្យសិស្សស្រាវជ្រាវឲ្យបានច្រើន(បណ្ណាល័យគួរតែបើកឲ្យបានយូរជាងមុនដើម្បីតម្រូវគ្រប់ម៉ោងសិក្សារបស់និស្សិត) និងផ្តល់ឱកាសការងារទាក់ទងនឹងជំនាញឲ្យបានច្រើន ដើម្បីសិស្សទទួលព័ត៌មានគ្រប់គ្រាន់មុននឹងបញ្ចប់ការសិក្សា។
- សម្រាប់ខ្ញុំ ការសិក្សាដែលត្រូវជំនាញ និងធ្វើការត្រូវជំនាញ គឺកើតពីខ្លួនឯងជាមុន ព្រោះកំលុងពេលសិក្សាប្រសិនជាយើងព្យាយាមស្វែងរកការងារហាត់ការណាដែរត្រូវជំនាញគឺជារឿងល្អជាងរកការងារមានប្រាក់ខែតែខុសជំនាញ។ ខ្ញុំសំណូមពរឲ្យសាលាដាក់ចេញជាកំហិតថា សិស្សឆ្នាំទី៣ ត្រូវចេញរកការងារស្ម័គ្រចិត្តមួយឲ្យសាលាជាកំហិត ដូចនៅមួយចំនួនដែរ។ ព្រោះដេប៉ាតឺម៉ង់ខ្ញុំ មានសិស្សច្រើនណាស់ដែលធ្វើការខុសជំនាញ និងខ្លះទៀតចប់ហើយមិនដឹងធ្វើអ្វី។ អ្នកខ្លះក៏មិនបានដឹងថា អ្វីជាការងារហាត់ការយកបទពិសោធទៀត។ ដើម្បីពង្រឹងសមត្ថភាពនិស្សិត គួរបយល់នូវអ្វីដែលមានសារៈសំខាន់ក្នុងមុខវិជ្ជាដែលជម្រុញដល់តម្រូវការការងារ។

## ឧបសម្ព័ន្ធ២៖ កម្រងសំណួរ

# សាកលវិទ្យាល័យភូមិន្ទ ភ្នំពេញ
# ការិយាល័យធានាគុណភាព

# កម្រងសំណួរស្រាវជ្រាវស្តីពីលទ្ធភាពស្វែងរកការងារ
# របស់អតីតនិស្សិតស.ភ.ភ.ព ២០២២

ការសិក្សានេះមានគោលបំណងស្ទាបស្ទង់មតិអំពីលទ្ធភាពស្វែងរកការងាររបស់និស្សិតដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ(ស.ភ.ភ.ព.)ក្នុងឆ្នាំសិក្សា២០២១-២០២២កន្លងមក។ លទ្ធផលដែលទទួលបានពីការសិក្សានេះ នឹងរួមចំណែកលើកកម្ពស់កម្មវិធីសិក្សានៅសាកលវិទ្យាល័យឱ្យកាន់តែមានភាពប្រសើរ ស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិ ដើម្បីឆ្លើយតបតម្រូវការទីផ្សារការងារ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ សូមអរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមបំពេញកម្រងសំណួរ របស់លោក លោកស្រី អ្នកនាង កញ្ញា។ សូមទទួលបានជោគជ័យក្នុងការងារអាជីពបន្ថែមទៀត។ យើងសូមរក្សាការសម្ងាត់រាល់ព័ត៌មាននិងការឆ្លើយតបរបស់លោកអ្នកដែលបានផ្តល់ជូនដោយអនាមិក។ យើងនឹងមិនប្រើមធ្យោបាយបច្ចេកវិទ្យា ឬមិនមែនបច្ចេកទេសណាមួយដើម្បីតាមដានការឆ្លើយតបរបស់បុគ្គលណាម្នាក់ ក្នុងការស្ទង់មតិនេះទេ។

សូមអរគុណ

ខ្ញុំស្ម័គ្រចិត្តចូលរួមផ្តល់មតិលើការសិក្សានេះ ដើម្បីលើកកម្ពស់វិធីសិក្សាសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ហើយខ្ញុំមានសិទ្ធិគ្រប់គ្រាន់ក្នុងការដកខ្លួន ឬមិនផ្តល់ចម្លើយលើសំណួរណាមួយពីការសិក្សានេះ។

☐ 1. ព្រម ☐ 2. មិនព្រម(អ្នកមិនចាំបាច់បន្តទេ)

## I. ព័ត៌មានផ្ទាល់ខ្លួន

1. តើអ្នកបានសិក្សារៀនសូត្រ នៅសាកលវិទ្យាល័យផ្សេងក្រៅពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញដែរ ឬទេ ?

   ☐ 1. បាទ/ចាស ☐ 2. ទេ

2. ហេតុអ្វី អ្នកជ្រើសរើសចូលមកសិក្សារៀនសូត្រ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ? (អាចជ្រើសរើសចម្លើយច្រើនជាងមួយ)

   ☐ 1. គ្រឹះស្ថានបានផ្តល់អាហារូបករណ៍

   ☐ 2. គ្រឹះស្ថាននៅជិតទីលំនៅ

   ☐ 3. គ្រឹះស្ថានមានទីតាំងល្អ

☐ 4. គ្រឹះស្ថានមានភាពទាក់ទាញគួរឲ្យចង់សិក្សា

☐ 5. គ្រឹះស្ថានមានកេរ្តិ៍ឈ្មោះ/កិត្តិស័ព្ទល្បីល្បាញ

☐ 6. គ្រឹះស្ថានមានការអប់រំប្រកបដោយគុណភាព

☐ 7. គ្រឹះស្ថានផ្តល់ការអប់រំដោយផ្តោតលើការអនុវត្តជាក់ស្តែង

☐ 8. មានឱកាសការងារខ្ពស់/ងាយរកការងារធ្វើ

☐ 9. គ្រឹះស្ថានមានអន្តេវាសិកដ្ឋានសម្រាប់និស្សិតស្នាក់នៅ

☐ 10. ផ្សេងៗ

3.ភេទ: 1. ☐ ប្រុស 2. ☐ ស្រី

4. អាយុ

☐ 1. ក្រោម ២១ឆ្នាំ ☐ 2. ២២-២៥ឆ្នាំ ☐ 3. ២៦-៣០ឆ្នាំ

☐ 4. ៣០-៣៥ឆ្នាំ ☐ 5. លើស ៣៥ឆ្នាំ

5. បច្ចុប្បន្នរស់នៅ

1. រាជធានីភ្នំពេញ
2. ខេត្តកណ្តាល
3. ខេត្តកំពង់ស្ពឺ
4. ខេត្តតាកែវ
5. ខេត្តកំពត
6. ខេត្តកែប
7. ខេត្តព្រះសីហនុ (កំពង់សោម)
8. ខេត្តកោះកុង
9. ខេត្តប៉ៃលិន
10. ខេត្តពោធិសាត់
11. ខេត្តបាត់ដំបង
12. ខេត្តបន្ទាយមានជ័យ
13. ខេត្តឧត្តរមានជ័យ
14. ខេត្តសៀមរាប
15. ខេត្តកំពង់ចាម
16. ខេត្តកំពង់ធំ
17. ខេត្តកំពង់ឆ្នាំង

18. ខេត្តព្រៃវែង
19. ខេត្តត្បូងឃ្មុំ
20. ខេត្តស្វាយរៀង
21. ខេត្តក្រចេះ
22. ខេត្តស្ទឹងត្រែង
23. ខេត្តរតនៈគិរី
24. ខេត្តមណ្ឌលគិរី
25. ខេត្តព្រះវិហារ

6. លេខទូរស័ព្ទ: [ ]

7. អ៊ីម៉ែល/ហ្វេសបុក: [ ]

8. ស្ថានភាពគ្រួសារ

☐ 1. រៀបការ ☐ 2. នៅលីវ ☐ 3. លែងលះ

9. អតីតនិស្សិត

☐ 1. អាហារូបករណ៍ ☐ 2. សិក្សាបង់ថ្លៃ

10. អ្នកបានបញ្ចប់ការសិក្សាកម្រិត

☐ 1. បរិញ្ញាបត្រ ☐ 2.បរិញ្ញាបត្រជាន់ខ្ពស់ ☐ 3. បណ្ឌិត

11. អ្នកចូលសិក្សាឆ្នាំណា ?

☐ 1. ២០១៧-២០១៨ ☐ 2. ២០១៨-២០១៩ ☐ 3. ផ្សេងៗ

12. អ្នកបានបញ្ចប់ការសិក្សានៅឆ្នាំ ២០២១-២០២២

☐ 1. បាទ/ចាស ☐ 2. ទេ

13. តើអ្នកជាអតីតនិស្សិតក្នុងមហាវិទ្យាល័យមួយណា ?

1. មហាវិទ្យាល័យ វិទ្យាសាស្ត្រ
2. មហាវិទ្យាល័យ សង្គមសាស្ត្រនិងមនុស្សសាស្ត្រ
3. មហាវិទ្យាល័យ វិស្វកម្ម
4. មហាវិទ្យាល័យ សិក្សាអភិវឌ្ឍន៍
5. មហាវិទ្យាល័យ អប់រំ
6. វិទ្យាស្ថាន ភាសាបរទេស

14. មុខជំនាញដែលបានសិក្សា

1. ដេប៉ាតឺម៉ង់ ទេសចរណ៍(DOT)
2. ដេប៉ាតឺម៉ង់ ភូមិវិទ្យា(GLM)

3. ដេប៉ាតឺម៉ង់ ប្រវត្តិវិទ្យា( DOH )
4. ដេប៉ាតឺម៉ង់ អក្សរសាស្ត្រខ្មែរ( DKL )
5. ដេប៉ាតឺម៉ង់ ទស្សនវិជ្ជា( DOP )
6. ដេប៉ាតឺម៉ង់ ចិត្តវិទ្យា( DPS )
7. ដេប៉ាតឺម៉ង់ សង្គមវិទ្យា( DOS )
8. ដេប៉ាតឺម៉ង់ ប្រព័ន្ធផ្សព្វផ្សាយ( DMC )
9. ដេប៉ាតឺម៉ង់ រូបវិទ្យា( DPH )
10. ដេប៉ាតឺម៉ង់ គីមីវិទ្យា( DCH )
11. ដេប៉ាតឺម៉ង់ ជីវវិទ្យា( DOB )
12. ដេប៉ាតឺម៉ង់ ព័ត៌មានវិទ្យា( CSD )
13. ដេប៉ាតឺម៉ង់ បរិស្ថានវិទ្យា( DES )
14. ដេប៉ាតឺម៉ង់ គណិតវិទ្យា( DOM )
15. ដេប៉ាតឺម៉ង់ ភាសាអង់គ្លេស( DOE )
16. ដេប៉ាតឺម៉ង់ ភាសាបារាំង ( DOF )
17. ដេប៉ាតឺម៉ង់ ភាសាជប៉ុន( DOJ )
18. ដេប៉ាតឺម៉ង់ ភាសាកូរ៉េ( DOK )
19. ដេប៉ាតឺម៉ង់ សង្គមកិច្ចវិទ្យា( DSW )
20. ដេប៉ាតឺម៉ង់ ភាសាចិន( DCH )
21. ដេប៉ាតឺម៉ង់ សិក្សាអន្តរជាតិ( DIS )
22. ដេប៉ាតឺម៉ង់ គ្រប់គ្រងពាណិជ្ជកម្ម( IBM )
23. ដេប៉ាតឺម៉ង់ អភិវឌ្ឍន៍សេដ្ឋកិច្ច( DED )
24. ដេប៉ាតឺម៉ង់ គ្រប់គ្រង និងអភិវឌ្ឍន៍ធនធានធម្មជាតិ( DNRMD )
25. ដេប៉ាតឺម៉ង់ អភិវឌ្ឍន៍សហគមន៍( DCD )
26. ដេប៉ាតឺម៉ង់ វិស្វកម្មទូរគមនាគមន៍និងអេឡិចត្រូនិច( TEED )
27. ដេប៉ាតឺម៉ង់ វិស្វកម្មជីវសាស្ត្រ( BED )
28. ដេប៉ាតឺម៉ង់ វិស្វកម្មបច្ចេកវិទ្យាព័ត៌មាន( ITE )
29. ដេប៉ាតឺម៉ង់ ភាសាថៃ( DTH )
30. ដេប៉ាតឺម៉ង់ ភាសាវិទ្យា( DL )
31. ដេប៉ាតឺម៉ង់ អប់រំពេញមួយជីវិត( DLL )
32. ដេប៉ាតឺម៉ង់ សិក្សាអប់រំ( DES )

33. ដេប៉ាតឺម៉ង់ គ្រប់គ្រង និងអភិវឌ្ឍឧត្តមសិក្សា(DHEDM)

34. ផ្សេងៗ

## II. ព័ត៌មានសិក្សា

(ចំណេះដឹងនិងសមត្ថភាពទទួលបានពីការសិក្សា)

15. តើអ្នកបានទទួលចំណេះដឹងជំនាញសតវត្សទី២១ ក្នុងកម្រិតណាពីការសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ? ១=មិនទទួលបានទាល់តែសោះ ៥=ទទួលបានខ្ពស់ណាស់

1. ចំណេះដឹងក្នុងការគិត
2. ចំណេះដឹងច្នៃប្រឌិត
3. សមត្ថភាពធ្វើការជាក្រុម
4. សមត្ថភាពក្នុងការទំនាក់ទំនង
5. ចំណេះដឹងអំពីព័ត៌មានវិទ្យា
6. ចំណេះដឹងអំពីប្រព័ន្ធផ្សព្វផ្សាយ
7. សមត្ថភាពប្រើប្រាស់បច្ចេកវិទ្យា
8. ឥរិយាបថបត់បែនទន់ភ្លន់
9. ភាពជាអ្នកដឹកនាំ
10. ចំណេះដឹងក្នុងការផ្តួចផ្តើមគំនិតអភិវឌ្ឍន៍
11. ជំនាញអាចចូលរួមការងារក្នុងសង្គម
12. សមត្ថភាពស្រាវជ្រាវ
13. សមត្ថភាពវិភាគទិន្នន័យ
14. ចំណេះដឹងភាសាអង់គ្លេស

16. តើអ្នកមានការពេញចិត្តចំពោះគុណភាពនៃការរៀននិងបង្រៀនរបស់គ្រឹះស្ថានក្នុងកម្រិតណា? ១=មិនពេញចិត្តទាល់តែសោះ ៥=ពេញចិត្តខ្លាំងណាស់

1. គ្រូមានកម្រិតសញ្ញាបត្រខ្ពស់
2. គ្រូមានកម្រិតចំណេះដឹងខ្ពស់
3. គ្រូមានបទពិសោធន៍បង្រៀនច្រើនឆ្នាំ
4. គ្រូមានសមត្ថភាពបង្រៀនបានល្អ
5. គ្រូមានឥរិយាបថ និងក្រមសីលធម៌ល្អក្នុងការបង្រៀន
6. មុខវិជ្ជាបង្រៀនស្របនឹងជំនាញរបស់គ្រូ

7. ការរៀបចំមេរៀន និងការបង្រៀនមានគុណភាព
8. ការបង្រៀនបានចប់តាមកម្មវិធីមេរៀនទាន់ពេលវេលា
9. និស្សិតទទួលបានការជំរុញនិងលើកទឹកចិត្តពីគ្រូ
10. មុខវិជ្ជាមានឧបករណ៍/សម្ភារប្រើប្រាស់សម្រាប់បង្រៀនបានត្រឹមត្រូវ
11. គ្រូបានយកលទ្ធផលស្រាវជ្រាវនិងរបកគំហើញថ្មីៗមកបង្ហាត់បង្ហាញ
12. គ្រូវាយតម្លៃការសិក្សារបស់និស្សិតត្រឹមត្រូវ

## III. បទពិសោធន៍ការងារក្នុងពេលសិក្សានៅស.ភ.ភ.ព

(សូមបង្ហាញអំពីស្ថានភាពការងាររបស់អ្នក)

17. មុនចូលមកសិក្សានៅស.ភ.ភ.ព តើអ្នកធ្លាប់មានការងារធ្វើដែរឬទេ?
(បើអត់មាន សូមរំលង សំណួរ១៨ ដល់២២)

☐ 1. មាន ☐ 2. អត់មាន

18. តួនាទីកន្លែងការងារ
1. ប្រធាន
2. អនុប្រធាន
3. អ្នកគ្រប់គ្រងផ្នែក
4. អ្នកបច្ចេកទេស
5. គ្រូបង្រៀនពេញសិទ្ធ
6. គ្រូបង្រៀនកិច្ចសន្យា
7. បុគ្គលិក/មន្ត្រីពេញសិទ្ធ
8. បុគ្គលិកកិច្ចសន្យា
9. អ្នកហាត់ការលើជំនាញ
10. ការងារបណ្តោះអាសន្ន
11. ផ្សេងៗ

19. ស្ថានប័នបម្រើធ្លាប់ការងារ
1. អប់រំសាធារណៈ
2. អប់រំឯកជន
3. ស្ថាប័នរដ្ឋាភិបាល

4. អង្គការក្រៅរដ្ឋាភិបាល
5. ក្រុមហ៊ុនឯកជន
6. ជំនួញផ្ទាល់ខ្លួន
7. ផ្សេងៗ

20. តើអ្នកធ្វើការងារជាប្រភេទបែបណា ?

☐ 1. ពេញម៉ោង 2. ☐ ក្រៅម៉ោង ☐ 3. ផ្សេងៗ

21. តើអ្នកនៅបន្តធ្វើការងារនេះដែរឬទេពេលកំពុងរៀន ?

☐ 1.កំពុងបន្ត ☐ 2. អត់ទេ ☐ 3. ផ្សេងៗ

22. រយៈពេលបំពេញការងារ (ខែឬឆ្នាំ)

☐ 1.តិចជាង១២ ខែ ☐ 2. ចន្លោះ១ឆ្នាំទៅ២ឆ្នាំ ☐ 3. ចន្លោះ៣ឆ្នាំទៅ៥ឆ្នាំ

☐ 4. ច្រើនជាង៦ឆ្នាំ ☐ 5. ផ្សេងៗ

23. ក្នុងពេលសិក្សានៅស.ភ.ភ.ព តើអ្នកធ្លាប់មានការងារធ្វើដែរឬទេ ?
(បើអត់មាន សូមរំលងសំណួរ២៤ដល់២៧)

☐ 1. មាន ☐ 2. អត់មាន

24. តួនាទីកន្លែងបម្រើការងារ

1. ប្រធាន
2. អនុប្រធាន
3. អ្នកគ្រប់គ្រងផ្នែក
4. អ្នកបច្ចេកទេស
5. គ្រូបង្រៀនពេញសិទ្ធ
6. គ្រូបង្រៀនកិច្ចសន្យា
7. បុគ្គលិក/មន្ត្រីពេញសិទ្ធ
8. បុគ្គលិកកិច្ចសន្យា
9. អ្នកហាត់ការលើជំនាញ
10. ការងារបណ្តោះអាសន្ន
11. ផ្សេងៗ

25. ស្ថានប័នធ្លាប់បម្រើការងារ

1. អប់រំសាធារណៈ
2. អប់រំឯកជន
3. ស្ថាប័នរដ្ឋាភិបាល
4. អង្គការក្រៅរដ្ឋាភិបាល
5. ក្រុមហ៊ុនឯកជន
6. ជំនួញផ្ទាល់ខ្លួន
7. ផ្សេងៗ

26. តើអ្នកធ្វើការងារជាប្រភេទបែបណា?

☐ 1. ពេញម៉ោង ☐ 2. ក្រៅម៉ោង ☐ 3. ផ្សេងៗ

27. **សុំអធ្យាស្រ័យ**តើអ្នកទទួលប្រាក់បៀវត្ស(រៀលឬដុល្លា)ប្រចាំខែប្រហែលប៉ុន្មានដែរ?

☐ ១. គ្មាន
☐ ២. តិចជាង១០០ដុល្លា
☐ ៣. ចន្លោះពី១០០ដុល្លាទៅ១៥០ដុល្លា
☐ ៤. ចន្លោះពី១៥១ដុល្លាទៅ២០០ដុល្លា
☐ ៥. ច្រើនជាង២០០ដុល្លា

28. តើអ្នកមានប្រាក់ឧបត្ថម្ភ ឬប្រាក់អត្ថប្រយោជន៍ផ្សេងៗដែរទេ?

☐ 1. មាន ☐ 2.អត់មាន

29. ប្រាក់ឧបត្ថម្ភ ឬអត្ថប្រយោជន៍ផ្សេងៗដែលទទួលបានមាន
(ចម្លើយច្រើនជាងមួយ)

1. សោហ៊ុយធ្វើដំណើរ
2. ឱកាសទទួលបានការងារទីនោះ
3. លើកកម្ពស់សមត្ថភាព
4. ប្រាក់ឧបត្ថម្ភសុខភាព
5. ប្រាក់ឧបត្ថម្ភលើកទឹកចិត្តបន្តិចបន្តួច
6. គ្មាន/ផ្សេងៗ

30. រយៈពេលបំពេញការងារ(ខែឬឆ្នាំ)

☐ ១.តិចជាង១២ ខែ ☐ ២.ចន្លោះ១ឆ្នាំទៅ២ឆ្នាំ ☐ ៣.ចន្លោះ៣ឆ្នាំទៅ៤ឆ្នាំ

☐ ៤.ច្រើនជាង៥ឆ្នាំ ☐ ៥.ផ្សេងៗ

31. តើអ្នកមានការងារធ្វើក្នុងពេលកំពុងសិក្សាក្នុងឆ្នាំណា?

☐ 1.ឆ្នាំទី១ ☐ 2. ឆ្នាំទី២ ☐ 3. ឆ្នាំទី៣

☐ 4. ឆ្នាំទី៤ ☐ 5. មុនចូលសិក្សា ☐ 6. ផ្សេងៗ

32. តើក្នុងពេលកំពុងសិក្សា អ្នកនៅបន្តធ្វើការងារនេះដែរឬទេ?

☐ ១.កំពុងបន្ត ☐ ២.អត់ទេ ☐ ៣.ផ្សេងៗ

## IV. ស្ថានភាពការងារក្រោយបញ្ចប់ការសិក្សា

(សូមបង្ហាញស្ថានភាពទទួលបានការងាររបស់អ្នកក្រោយបញ្ចប់ការសិក្សា)

33. តើសព្វថ្ងៃអ្នកមានការងារមួយធ្វើពិតប្រាកដដែរឬទេ?

(បើអត់មាន សូមរំលងទៅសំណួរ៣៤ ដល់៤៤)

☐ 1. មាន ☐ 2. អត់មាន

34. តួនាទីកន្លែងបម្រើការងារ

1. ប្រធាន
2. អនុប្រធាន
3. អ្នកគ្រប់គ្រងផ្នែក
4. អ្នកបច្ចេកទេស
5. គ្រូបង្រៀនពេញសិទ្ធ
6. គ្រូបង្រៀនកិច្ចសន្យា
7. បុគ្គលិក/មន្ត្រីពេញសិទ្ធ
8. បុគ្គលិកកិច្ចសន្យា
9. អ្នកហាត់ការលើជំនាញ
10. ការងារបណ្តោះអាសន្ន
11. ផ្សេងៗ

35. ស្ថានប័នធ្លាប់បម្រើការងារ

1. អប់រំសាធារណៈ
2. អប់រំឯកជន
3. ស្ថាប័នរដ្ឋាភិបាល
4. អង្គការក្រៅរដ្ឋាភិបាល
5. ក្រុមហ៊ុនឯកជន
6. ជំនួញផ្ទាល់ខ្លួន
7. ផ្សេងៗ

36. តើអ្នកកំពុងធ្វើការងារជាប្រភេទបែបណា?

☐ 1. ពេញម៉ោង ☐ 2. ក្រៅម៉ោង ☐ 3. ផ្សេងៗ

37. រយៈពេលបំពេញការងារ(ខែឬឆ្នាំ)

☐ ១.តិចជាង១២ ខែ ☐ ២.ចន្លោះ១ឆ្នាំទៅ២ឆ្នាំ ☐ ៣.ចន្លោះ៣ឆ្នាំទៅ៤ឆ្នាំ
☐ ៤.ច្រើនជាង៥ឆ្នាំ ☐ ៥.ផ្សេងៗ

38. **សុំអធ្យាស្រ័យ**តើអ្នកទទួលប្រាក់បៀវត្ស(រៀលឬដុល្លា)ប្រចាំខែប្រហែលប៉ុន្មានដែរ?

☐ ១.តិចជាង១០០ដុល្លា
☐ ២.ចន្លោះពី១០១ដុល្លាទៅ១៥០ដុល្លា
☐ ៣.ចន្លោះពី១៥១ដុល្លាទៅ២៥០ដុល្លា
☐ ៤.ចន្លោះពី២៥១ដុល្លាទៅ៣៥០ដុល្លា
☐ ៥.ចន្លោះពី៣៥១ដុល្លាទៅ៤៥០ដុល្លា
☐ ៦.ចន្លោះពី៤៥១ដុល្លាទៅ៥៥០ដុល្លា
☐ ៧.ចន្លោះពី៥៥១ដុល្លាទៅ៦៥០ដុល្លា
☐ ៨.ចន្លោះពី៦៥១ដុល្លាទៅ៧៥០ដុល្លា
☐ ៩.ចន្លោះពី៧៥១ដុល្លាទៅ៨៥០ដុល្លា
☐ ១០.ចន្លោះពី៨៥១ដុល្លាទៅ១០០០ដុល្លា
☐ ១១.ចន្លោះពី១០០១ដុល្លាទៅ១៥០០ដុល្លា
☐ ១២.ចន្លោះពី១៥០១ដុល្លាទៅ២០០០ដុល្លា
☐ ១៣. ច្រើនជាង២០០០ដុល្លា

39. តើអ្នកមានប្រាក់ឧបត្ថម្ភ ឬអត្ថប្រយោជន៍ផ្សេងៗក្រៅពីប្រាក់បៀវត្សដែរទេ?

☐ 1. មាន ☐ 2.អត់មាន ☐ 3. ផ្សេងៗ

40. ប្រាក់ឧបត្ថម្ភ ឬអត្ថប្រយោជន៍ផ្សេងៗដែលទទួលបានមាន

☐ 1.ឱកាសតម្លើងឋានៈ ☐ 2.ឱកាសតម្លើងប្រាក់បៀវត្ស ☐ 3.លើកកម្ពស់សមត្ថភាព

☐ 4. ប្រាក់សុខភាព ☐ 5. ផ្សេងៗ

41. តើអ្នកកំពុងប្រើប្រាស់ជំនាញដែលបានពីការសិក្សាពីស.ភ.ភ.ព.ដែរឬទេ?

☐ 1.កំពុងប្រើ ☐ 2. អត់ទេ

42. តើជំនាញដែលអ្នកទទួលបានសិក្សានៅស.ភ.ភ.ព.ផ្តល់ភាពងាយស្រួលឲ្យអ្នកស្វែងរកការងារបច្ចុប្បន្នដែរឬទេ?

☐ 1. បាន ☐ 2. អត់ទេ

43. ក្រោយបញ្ចប់ការសិក្សាពីស.ភ.ភ.ព.តើអ្នកប្រើរយៈពេលប៉ុន្មាន ដើម្បីរកការងារមួយបានធ្វើ?

☐ 1. តិចជាង ៣ខែ ☐ 2. ចន្លោះ ៣ខែ ទៅ ៦ខែ 3. ចន្លោះពី ៧ខែ ទៅ ៩ខែ

☐ 4. ចន្លោះពី ១០ខែ ទៅ ១២ខែ ☐ 5. ច្រើនជាង១២ខែ ☐ 6. ផ្សេងៗ

44. តើអ្នកធ្លាប់បានប្រើវិធីសាស្ត្រអ្វីខ្លះពេលស្វែងរកការងារ? (ចម្លើយអាចច្រើនជាងមួយ)

1. ការិយាល័យវិជ្ជាជីវៈរបស់ស.ភ.ភ.ព.
2. ការផ្សព្វផ្សាយរបស់ស.ភ.ភ.ព.
3. ការប្រឡងចូលក្របខណ្ឌ
4. សមាគមន៍និស្សិតរបស់ស.ភ.ភ.ព.
5. គ្រួសារ/មិត្តភក្តិ/អ្នកស្គាល់គ្នា
6. ការបិតផ្សាយសាធារណៈ
7. ទាក់ទងផ្ទាល់ជាមួយនិយោជក
8. ការផ្សព្វផ្សាយលើប្រព័ន្ធអ៊ីនធឺណែត
9. ការជូនដំណឹងផ្ទាល់របស់ក្រសួងសាមី
10. ផ្សេងៗ

## V. ទស្សនៈរបស់អតីតនិស្សិតអំពីការសិក្សានិងចំណិនដែលទាក់ទងទីផ្សារការងារ

**សម្គាល់៖** ១=មិនសំខាន់/ពេញចិត្តទាល់តែសោះ ៥=សំខាន់/ពេញចិត្តខ្លាំងណាស់

45. សូមជ្រើសយកនិទស្សន៍ដែលសមស្របទស្សនៈយល់ឃើញរបស់អ្នកខាងក្រោម៖

១=មិនសំខាន់ទាល់តែសោះ ៥=សំខាន់ខ្លាំងណាស់

1. ជំនាញដែលអ្នកសិក្សានៅពីស.ភ.ភ.ព.ជួយអ្នកឲ្យទទួលបានអាជីពបច្ចុប្បន្នរបស់អ្នក
2. មុខវិជ្ជាដែលអ្នកសិក្សានៅពីស.ភ.ភ.ព.បានជួយតម្រង់ទិសអ្នកឲ្យចាប់យកអាជីពបច្ចុប្បន្ន
3. ការសិក្សានៅស.ភ.ភ.ព.បានផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្ត
4. អ្នកកំពុងប្រើប្រាស់ចំណេះដឹងនិងជំនាញដែលបានសិក្សាពីស.ភ.ភ.ព.
5. អ្នកកំពុងប្រើប្រាស់ចំណេះដឹងនិងជំនាញដែលបានសិក្សានៅស.ភ.ភ.ព.សម្រាប់ការងារបច្ចុប្បន្ន
6. មុខវិជ្ជាទាំងអស់ដែលអ្នកសិក្សាមានប្រយោជន៍ចំពោះអាជីពអ្នកខ្លាំងណាស់
7. ជំនាញដែលបានការសិក្សាកន្លងមកមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយការងារដែលអ្នកកំពុងធ្វើ
8. ចំណេះដឹងដែលអ្នកទទួលបានពីស.ភ.ភ.ព.កំពុងតែជាតម្រូវការចាំបាច់សម្រាប់សង្គមកម្ពុជា
9. ការសិក្សានៅស.ភ.ភ.ព.ជួយអ្នកឲ្យមានសមត្ថភាពវិភាគនិងដោះស្រាយបញ្ហារប្រឈមនានាក្នុងការងារប្រចាំថ្ងៃ
10. ការសិក្សានៅស.ភ.ភ.ព.បានជួយឲ្យអ្នកមានឱកាសទទួលបានការងារមួយសមស្រប
11. ការសិក្សានៅស.ភ.ភ.ព.បានជួយឲ្យអ្នកមានសមត្ថភាពទំនាក់ទំនងការងារល្អ
12. ការសិក្សានៅស.ភ.ភ.ព.បានជួយឲ្យអ្នកមានសមត្ថភាពច្នៃប្រឌិត
13. ការសិក្សានៅស.ភ.ភ.ពបានជួយអ្នកឲ្យមានសមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័តមាន(ICT)
14. ចំណេះនិងជំនាញរបស់អ្នកអាចជួយអ្នកបង្កើតសហគ្រិនភាពផ្ទាល់ខ្លួន
15. អ្នកទទួលបានចំណេះដឹងភាសាអង់គ្លេសពីស.ភ.ភ.ព.ល្មមប្រើបាស់បាន
16. កម្មវិធីសិក្សារបស់អ្នក តម្រូវឱ្យអ្នកចូលរួមហាត់ការមុនបញ្ចប់ការសិក្សា
17. ហាត់ការឬចុះកម្មសិក្សាមុនបញ្ចប់ការសិក្សាជួយអ្នកឱ្យទទួលបានការងារបច្ចុប្បន្ន
18. ក្រោយបញ្ចប់ការសិក្សា អ្នកមានសមត្ថភាពពេញលេញសម្រាប់បម្រើការងារបច្ចុប្បន្ន
19. អ្នកចង់ឲ្យមាននិស្សិតក្រោយៗសិក្សាមុខវិជ្ជាដូចអ្នកឲ្យបានច្រើន
20. អ្នកពេញចិត្តជាមួយចំណេះដឹងនិងគុណភាពអប់រំដែលអ្នកបានទទួលពី ស.ភ.ភ.ព.

46. ការពេញចិត្តកម្មវិធីសិក្សា

១=មិនពេញចិត្តទាល់តែសោះ ៥=ពេញចិត្តខ្លាំងណាស់

1. កម្មវិធីសិក្សា ឆ្លើយតបនឹងទីផ្សារការងារ
2. កម្មវិធីសិក្សា ជួយអ្នកឱ្យទទួលបានការងារធ្វើ
3. កម្មវិធីសិក្សា ឆ្លើយតបនឹងតម្រូវការជាក់ស្តែងសង្គម

4. កម្មវិធីសិក្សា ស្របតាមគោលនយោបាយជាតិ
5. កម្មវិធីសិក្សា បរិបទសាកល និងការអភិវឌ្ឍ
6. កម្មវិធីអប់រំ ផ្សារភ្ជាប់ជាមួយការស្រាវជ្រាវ
7. ការចូលរួមនិង ធ្វើបទបង្ហាញនៅសន្និសីទនានា
8. ការបោះពុម្ពទស្សនាវដ្តីវិទ្យាសាស្ត្រ ឬនិក្ខេបបទ

47. ការពេញចិត្តសេវាកម្មផ្តល់ដោយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

១=មិនពេញចិត្តទាល់តែសោះ ៥=ពេញចិត្តខ្លាំងណាស់

1. បរិយាកាសថ្នាក់រៀន សមស្របនឹងចំនួននិស្សិត
2. បរិស្ថានទូទាំងគ្រឹះស្ថានល្អ
3. ទីកន្លែងផ្ញើយានជំនិះសមស្របងាយស្រួលចតយានជំនិះ
4. អាហារដ្ឋាន មានសេវាសមរម្យសម្រាប់និស្សិត
5. និស្សិតទទួលបានសេវាប្រឹក្សាលើការសិក្សា
6. និស្សិតទទួលបានសេវាប្រឹក្សាផ្លូវចិត្ត
7. គ្រឹះស្ថានមានសេវាសុខភាព និងកម្មវិធីអប់រំសុខភាព
8. និស្សិតមានយន្តការតវ៉ា បញ្ចេញមតិក្នុងន័យស្ថាបនា
9. គ្រឹះស្ថានមានសេវាជួយនិស្សិតស្វែងរកការងារធ្វើ

48. ការពេញចិត្តសកម្មភាពកិច្ចការសង្គម

1. អាចចូលរួមព្រឹត្តិការសង្គម និងសហគមន៍
2. ចូលរួមការងារស្ម័គ្រចិត្តការងារសង្គម
3. អាចធ្វើការស្រាវជ្រាវ ការច្នៃប្រឌិត និងនវានុវត្តន៍
4. អាចចូលរួមកម្មវិធីប្រឡងប្រកួតប្រជែង
5. និស្សិតអាចបង្កើតក្លិបសិស្សា
6. បណ្ណាល័យមានឯកសារស្រាវជ្រាវគ្រប់គ្រាន់
7. មានបន្ទប់សិក្សាស្រាវជ្រាវឬពិសោធន៍គ្រប់គ្រាន់
8. បំពាក់ប្រព័ន្ធ Internet និង Wifi សម្រាប់ការសិក្សាទូលំទូលាយ

49. ទស្សនាទានអំពីការងាររបស់អ្នកក្នុងពេលបច្ចុប្បន្ន

១=មិនសំខាន់ទាល់តែសោះ ៥=សំខាន់ខ្លាំងណាស់

1. អង្គភាព
2. មុខងារ/តួនាទី
3. ប្រាក់បៀវត្សរ៍

4. ប្រាក់លើកទឹកចិត្ត
5. ឱកាសតម្លើងឋានៈ
6. ការប្រើចំណេះដឹង និងបច្ចេកវិទ្យា
7. អាជីព និងការអភិវឌ្ឍជំនាញ
8. ទំហំការងារនៃការទទួលខុសត្រូវរបស់ខ្លួន
9. បរិយាកាសការងារ

50. ការងាររបស់អ្នកតម្រូវឱ្យប្រើប្រាស់ជំនាញសតវត្សន៍ទី២១ ក្នុងកម្រិតណា
១=មិនតម្រូវទាល់តែសោះ ៥=តម្រូវខ្លាំងណាស់
1. ចំណេះដឹងក្នុងការគិត
2. ចំណេះដឹងច្នៃប្រឌិត
3. សមត្ថភាពធ្វើការងារជាក្រុម
4. សមត្ថភាពក្នុងការទំនាក់ទំនង
5. ចំណេះដឹងអំពីព័ត៌មានវិទ្យា
6. ចំណេះដឹងអំពីប្រព័ន្ធផ្សព្វផ្សាយ
7. សមត្ថភាពប្រើប្រាស់បច្ចេកវិទ្យា
8. ឥរិយាបថបត់បែនទន់ភ្លន់
9. ភាពជាអ្នកដឹកនាំ
10. ចំណេះដឹងក្នុងការផ្តួចផ្តើមគំនិតអភិវឌ្ឍន៍
11. ជំនាញអាចចូលរួមការងារក្នុងសង្គម
12. សមត្ថភាពស្រាវជ្រាវ
13. សមត្ថភាពវិភាគទិន្នន័យ
14. ចំណេះដឹងភាសាអង់គ្លេស

51. សូមផ្តល់ឈ្មោះមុខវិជ្ជាចំនួនបីដែលមានសារៈសម្រាប់ការងាររបស់អ្នកបច្ចុប្បន្ន?(លេខ១=សំខាន់ជាងគេ)
1. ........................................................................................................
2. ........................................................................................................
3. ........................................................................................................

## VI. ការសិក្សាបន្ត ឬក្នុងពេលអនាគតរបស់អតីតនិស្សិតដែលបានបញ្ចប់ការសិក្សា

52. តើអ្នកមានបំណងចង់បន្តការសិក្សាទៀតទេ?
☐ 1.ចង់ ☐ 2. អត់ទេ

53. ក្រោយបញ្ចប់ការសិក្សាពីស.ភ.ភ.ព តើអ្នកបាន ឬកំពុងបន្តការសិក្សាទេ?

☐ 1.កំពុងបន្ត ☐ 2.អត់ទេ ☐ 3.ផ្សេងៗ

54. ក្រោយបញ្ចប់ការសិក្សាពីស.ភ.ភ.ព តើអ្នកបាន ឬកំពុងបន្តការសិក្សាបែបណា ?

☐ 1.អត់ទេ ☐ 2. សិក្សាបង់ថ្លៃ ☐ 3. អាហារូបករណ៍

55. ក្រោយបញ្ចប់ការសិក្សាពីស.ភ.ភ.ព តើអ្នកកំពុង ឬមានបំណងបន្តការសិក្សាក្នុងកម្រិតណាដែរ ?

☐ 1. បរិញ្ញាបត្រ+ (NIE+១) ☐ 2. បរិញ្ញាបត្រ+( NIE+២) ☐ 3.បរិញ្ញាបត្រជាន់ខ្ពស់ (Master)

☐ 4. បណ្ឌិត (Ph.D.) ☐ 5. បន្តបរិញ្ញាបត្រដដែល ☐ 6. មិនទាន់បានបន្តទេ

☐ 7.ផ្សេងៗពីខាងលើ

56. តើអ្នកមានបំណងចង់បន្តការសិក្សាបន្ថែមនៅឯណា ?

☐ 1. អត់ទេ ☐ 2. ស.ភ.ភ.ព. ☐ 3. ក្នុងស្រុក

☐ 4. ក្រៅស្រុក ☐ 5. ផ្សេងៗ

57. តើអ្នកចង់ត្រឡប់មកបន្តការសិក្សាបន្ថែមលើជំនាញដែលអ្នកទទួលបានពីស.ភ.ភ.ពដែរឬទេ ?

☐ 1.ចង់ ☐ 2. អត់ទេ

58. តើអ្នកចង់បន្តការសិក្សាតាមបែបណា ?

☐ 1. អត់ទេ ☐ 2. សិក្សាបង់ថ្លៃ ☐ 3. អាហារូបករណ៍

59. អ្នកមានលទ្ធភាពបន្តការសិក្សាតាមរយៈ

☐ 1. អត់ទេ ☐ 2. រកជំនួយថ្លៃសិក្សា ☐ 3. ស្វែងរកអាហារូបករណ៍

☐ 4. ទៅបរទេស ☐ 5. ផ្សេងៗ

60. តើអ្នកមានមតិអ្វីបន្ថែមអំពីទំនាក់ទំនងរវាងការសិក្សានៅស.ភ.ភ.ព.នឹងតម្រូវការទីផ្សារការងារកម្ពុជាបច្ចុប្បន្ន ?

________________________________________

________________________________________

________________________________________

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអតីតនិស្សិត លោក(គ្រូ) អ្នក(គ្រូ)អ្នកនាង កញ្ញាដែលបានចំណាយពេលវេលាដ៏មានតម្លៃបំពេញកម្រងសំណួរស្ទាបស្ទង់មតិអំពីស្ថានភាពការងារក្រោយបញ្ចប់ការសិក្សាពីស.ភ.ភ.ព.។ សូមជូនពរឲ្យប្អូនៗអតីតនិស្សិត លោក(គ្រូ) អ្នក(គ្រូ)អ្នកនាង កញ្ញាមានសុខភាពល្អនិងទទួលបានជោគជ័យក្នុងអាជីព។

# សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

- មហាវិទ្យាល័យវិទ្យាសាស្ត្រ
- មហាវិទ្យាល័យសង្គមសាស្ត្រនិងមនុស្សសាស្ត្រ
- មហាវិទ្យាល័យវិស្វកម្ម
- មហាវិទ្យាល័យសិក្សាអភិវឌ្ឍន៍
- មហាវិទ្យាល័យអប់រំ
- វិទ្យាស្ថានភាសាបរទេស
- មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន

មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ

